# សាក្សីជំនាញ ដេវីដ ឆេនដល័រ ចាប់ផ្តើមផ្តល់សក្ខីកម្ម ដោយមានការជំទាស់ពីមេធាវីការពារក្តីជារឿយៗ

ដោយ អេរីកា អេមព្រី

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២

*ប្រែសម្រួលដោយ ជា ផល្លា*

សំណុំរឿង ០០២ ប្រឆាំងនឹងជនត្រូវចោទ នួន ជា, ខៀវ សំផន និង អៀង សារី បានបន្តនៅថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ២០១២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្ទាប់ពីការឈប់សម្រាកមួយខែ។ ដំណើរការនីតិវិធីបានចាប់ផ្តើមដោយមានការចូលរួមពីអ្នកភូមិប្រមាណ ៥០០នាក់ មកពីខេត្តបន្ទាយមានជ័យ កំពង់ចាម និងបាត់ដំបង។ នៅពេលថ្ងៃ អ្នកភូមិប្រមាណ ១០០នាក់ មកពីស្រុកមុខកំពូលនៃខេត្តកណ្តាលក៏មកចូលរួមដែរ។

ភាគីទាំងអស់មានវត្តមានលើកលែងតែ អៀង សារី ដែលទទួលការអនុញ្ញាតឲ្យចាកចេញពីតុលាការ និងតាមដានដំណើរការនីតិវិធីនៅបន្ទប់ឃុំឃាំងដោយសារតែបញ្ហាសុខភាពរបស់គាត់។

មុនពេល ដេវីដ ឆេនដល័រ ផ្តល់សក្ខីកម្ម លោកប្រធាន និល ណុន ដែលជាប្រធានអង្គជំនុំជម្រះបានលើកឡើងពីបញ្ហាមួយចំនួន។ សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹង ពេជ អង្គ បានស្នើឲ្យតុលាការទទួលស្គាល់មេធាវីអន្តរជាតិថ្មីម្នាក់ដែលនឹងតំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៥ នាក់ ជាមួយនឹងសហមេធាវី ស៊ីន សូវ៉ន។ លោក និល ណុន បានទទួល ស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដោយថាគាត់មានសិទ្ធិ និងបុព្វសិទ្ធិស្មើនឹងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិដែរ។

ត្រឡប់ទៅពិភាក្សាពីបញ្ហាផ្សេង លោក និល ណុន បានលើកឡើងពីការពន្យារពេលដំណើរការនីតិវិធីដែលបានរៀបចំឲ្យបន្តនៅថ្ងៃច័ន្ទទី១៦ ខែកក្កដា ឆ្នាំ២០១២។ លោកបានបង្ហាញពីភាពសោកស្តាយចំពោះការពន្យារពេល ពីព្រោះសហព្រះរាជអាជ្ញាម្នាក់មានជំងឺមិនអាចចូលរួមសវនាការពិនិត្យលើ ដេវីដ ឆេនដល័រ ដែលជាសាក្សីជំនួស។ លោកបានរំឭកដល់ភាគីទាំងអស់ឲ្យត្រៀមខ្លួនត្រួតពិនិត្យលើសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីតាមលំដាប់លំដោយដើម្បីបញ្ចៀសនូវការរំខាន ដែលមិនចាំបាច់ដល់តារាងពេលវេលារបស់អង្គជំនុំជម្រះ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ♦ P.O.Box 1110 ♦ Phnom Penh ♦ Cambodia
t (855-23) 211-875 ♦ f (855-23) 210-358 ♦ dccam@online.com.kh ♦ www.dccam.org

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំដាក់ឯកសារ

បន្ទាប់មក លោកប្រធាន និល ណុន បានប្រកាសពីសេចក្តីសម្រេចរបស់តុលាការទៅលើពាក្យបណ្តឹងពីរ ដែលពាក្យបណ្តឹងមួយដាក់ដោយសហព្រះរាជអាជ្ញា និងមួយទៀតដោយមេធាវីការពារក្តី នួន ជា ។ ជាបឋម លោកប្រធាន និល ណុន ដោះស្រាយពីពាក្យបណ្តឹងរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យដាក់ឯកសារពីរ និងយកទៅប្រើប្រាស់ឯកសារនេះជាមួយនឹងសាក្សី ។ លោកប្រធាន និល ណុន បានធ្វើកំណត់សម្គាល់ថា អង្គជំនុំជម្រះធ្លាប់បានសម្រេចហើយថា សេចក្តីថ្លែងការណ៍របស់សាក្សីដែលធ្លាប់បានបង្ហាញនៅក្នុងសវនាការអាចដាក់ជាឯកសារនៅក្នុងអង្គជំនុំជម្រះបាន ។ លោកបានបន្តទៀតថា ឯកសារទាំងពីរដែលសហព្រះរាជអាជ្ញាចង់ដាក់ធ្លាប់ត្រូវបានសហចៅក្រមស៊ើបអង្កេតប្រើប្រាស់នៅអំឡុងពេលសម្ភាសន៍ជាមួយសាក្សីរួចទៅហើយ ។ ដូច្នេះ លោកបានសម្រេចថាឯកសារនេះគឺជាផ្នែកមួយនៃសេចក្តីថ្លែងការណ៍របស់សាក្សីលេខ TCW694 ដូច្នេះវាអាចដាក់បញ្ចូលជាឯកសារដោយផ្អែកលើវិធាន៨៣(៣) នៃវិធានផ្ទៃក្នុង ។ លោកប្រធាន និល ណុន បានបង្ហាញថា ការណែនាំបន្ថែមទៀតគឺត្រូវយោងទៅតាមសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដែលសុំឲ្យអង្គជំនុំជម្រះចេញដីកាស្នើឲ្យទៅសាក្សី ឬការិយាល័យសហចៅក្រមស៊ើបអង្កេតបង្ហាញពីចំណុចដែលមិនបានលើកឡើងនៅក្នុងឯកសារ ។

ត្រឡប់សំណើរបស់មេធាវីការពារក្តី នួន ជា លោកប្រធាន និល ណុន បានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយ ។ មេធាវីការពារក្តី នួន ជា បានស្នើសុំដាក់ឯកសារ២០ និងប្រើប្រាស់ឯកសារនោះនៅពេលពិនិត្យលើ ដេវីដ ឆេនដល័រ ដើម្បីពិនិត្យលើភាពជឿជាក់របស់សាក្សីជំនាញ ។ លោកប្រធាន និល ណុន បានលើកឡើងថាឯកសារទីមួយមិនស្របទៅតាមវិធាន ៨៧(៤) ទេ ។ លោកបានធ្វើកំណត់សម្គាល់ថាឯកសារដែលនៅសល់ទៀតមិនមាននៅក្នុងសំណុំឯកសារ និងឯកសារភាគច្រើនមិនមានជាភាសាខ្មែរ ឬបារាំងទេ ។ លោកបានធ្វើសម្គាល់ថា លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ឡើងផ្តល់សក្ខីកម្មនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ ដូច្នេះ សំណើរបស់មេធាវីការពារក្តីមិនអាចទទួលយកមកពិចារណាបានទេដោយសារតែពេលវេលា ហើយមេធាវីការពារក្តី នួន ជា មិនបានបកស្រាយពន្យល់ឲ្យច្បាស់លាស់ថាបានរកឃើញភ័ស្តុតាងនៅពេលណា និងដោយវិធីណា ដែលធ្វើឲ្យមានការពិបាកក្នុងការវិភាគលើឯកសារនេះ ។ លោក និល ណុន បានបញ្ចប់សេចក្តីសម្រេចជាផ្លូវការថាមេធាវីការពារក្តី នួន ជា មិនស្របទៅតាមវិធាន ៨៧(៤) ដូច្នេះអង្គជំនុំជម្រះបដិសេធនឹងសំណើពីអក្សរ B ដល់អក្សរ T ។

នៅពេលដែលសហមេធាវីអន្តរជាតិ នួន ជា អេនឌ្រូ ឡាន្ទូហ្ស៊ី បានព្យាយាមប្រឆាំងនឹងសេចក្តីសម្រេច លោក និល ណុន បានប្រកាន់គោលជំហរយ៉ាងមាំថា បញ្ហានេះត្រូវបានសម្រេចរួចហើយ ដូច្នេះលោក ឡាន្ទូហ្ស៊ី អាចធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការកំពូល ប្រសិនបើលោកមានការជំទាស់ ។ លោក ឡាន្ទូហ្ស៊ី បានឆ្លើយតបថា លោកកំពុងព្យាយាមកត់ត្រានូវសេចក្តីសម្រេច ។

សហមេធាវីអន្តរជាតិ អៀង សារី ម៉ៃខឹល ខាណាវ៉ាស បានឡើងនិយាយគាំទ្រមេធាវីរបស់ នួន ជា ថាមេធាវីរបស់ នួន ជា ប្រហែលជាគ្រាន់តែចង់ពន្យល់ពីសំណើរបស់ខ្លួន លោកប្រធាន និល ណុន បានកាត់ផ្តាច់មេក្រូរបស់លោក ខាណាវ៉ាស ដោយលើកឡើងថានេះមិនមែនជាបញ្ហារបស់លោកទេ ពីព្រោះនេះជាបញ្ហាដែលលើកឡើងដោយមេធាវីក្រុមផ្សេង ហើយបញ្ជាក់ម្តងទៀតថា អង្គជំនុំជម្រះនឹងមិនដោះស្រាយបញ្ហានេះទេ ។ នៅពេលលោក ខាណាវ៉ាស់ កំពុងតែនិយាយលោកប្រធាន និល ណុន មិនបានបើកមេក្រូឲ្យលោកទេ ។

លោកប្រធាន និល ណុន បានស្តាប់សម្តីរបស់ សហមេធាវី ខៀវ សំផន លោក អាកទួរ វែកកែន ដែលថា “ខ្ញុំគិតថា បញ្ហានេះក៏មានសារសំខាន់ចំពោះក្រុមទាំងមូលដែល ពីព្រោះយើងទាំងអស់គ្នាមានសិទ្ធិនឹងនិយាយ” ។ លោកប្រធាន និល ណុន អះអាងថា បញ្ហានេះត្រូវបានដោះស្រាយដោយមានប្រសិទ្ធភាពបន្ទាប់មកក៏បញ្ចប់ការសន្ទនា ។

## សំណួររបស់លោកប្រធាន និល ណុន ទៅកាន់សាក្សីទាក់ទងនឹងកម្រិតវប្បធម៌ និងការងារ

លោកប្រធាន និល ណុន បានសួរលោក ដេវីដ ឆេនដល័រ នូវសំណួរមួយចំនួនទាក់ទងនឹងកម្រិតវប្បធម៌ និងការស្រាវជ្រាវរបស់លោក ។ ខាងក្រោមនេះគឺជាចម្លើយដែលបានមកពីលោក ។

សាក្សីឈ្មោះ ដេវីដ ឆេនដល័រ មានអាយុ៧៩ឆ្នាំ សញ្ជាតិ អាមេរិក-អូស្ត្រាលី ។ បច្ចុប្បន្នលោករស់នៅទីក្រុងមេលប៊ិន នៃប្រទេសអូស្ត្រាលី ។ ខណៈពេលដែលលោកចូលនិវត្តន៍ លោកធ្វើជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យ ម៉ូណាស នៃរដ្ឋមែលបន ប្រទេសអូស្ត្រាលី ។ បន្ទាប់ពីបញ្ជាក់ថាលោកមិនមានទំនាក់ទំនងដោយសាច់ញាតិឬអាពាហ៍ពិពាហ៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ឬជនត្រូវចោទណាមួយ លោកបានធ្វើសច្ចាប្រណិធាន ។

ទាក់ទងនឹងការអប់រំ លោកបានរៀននៅសាលកវិទ្យាល័យហាវ៉ឺត បន្ទាប់មកនៅសាកលវិទ្យាល័យយេល និងសាកលវិទ្យាល័យមីឈីហ្គេន នៃសហរដ្ឋអាមេរិក ។ លោកបានអនុវត្តមុខជំនាញរបស់លោកនៅសាកលវិទ្យាល័យម៉ូណាស់អស់រយៈពេល២៥ឆ្នាំមុនពេលលោកចូលនិវត្តន៍ ។

លោក ឆេនដល័រ បាននិយាយថាលោកចេះនិយាយខ្មែរ ប៉ុន្តែមិនអាចសរសេរបានទេ។ ទាក់ទងនឹងប្រវត្តិរបស់លោក លោកបានរៀនប្រវត្តិសាស្ត្រកម្ពុជា និងរយៈកាលនៃរបបខ្មែរក្រហម តាំងពីពេលចាប់ផ្តើមមកដល់បច្ចុប្បន្ន។ សៀវភៅដែលលោកបានសរសេរទាក់ទងនឹងរបបខ្មែរក្រហមរួមមាន *ប្រវត្តិសាស្ត្រកម្ពុជា សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា បងធំទីមួយ និងសម្លេងពីស-២១*។ លោកបានសរសេរអត្ថបទមួយចំនួនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជា។ លោកបានរៀបរាប់ពីចំណាប់អារម្មណ៍របស់លោកទៅលើប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៦០ នៅពេលដែលលោកត្រូវបានចាត់តាំងឲ្យធ្វើជាគណៈប្រតិភូនៅស្ថានទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជា។ បន្ទាប់ពីសម្រេចចិត្តបន្តមុខងារនេះ លោកបានជ្រើសរើសយកជំនាញប្រវត្តិសាស្ត្រកម្ពុជា តាំងពីសម័យមុនអាណានិគមរហូតដល់សម័យទំនើប គឺបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច។

បន្ទាប់មក លោកប្រធាន និល ណុន បានលើកឡើងពីសៀវភៅរបស់លោកដែលមានចំណងជើងថា *សោកនាដកម្មរបស់កម្ពុជា* លោកបានចាប់ការងារនៅឆ្នាំ១៩៨៥ បោះពុម្ពនៅឆ្នាំ១៩៩១ និងកែសម្រួលបន្តិចបន្តួចនៅឆ្នាំ១៩៩២។ មិនមានការកែសម្រួលអ្វីទៀតទេចាប់ពីពេលនោះមក។ ទាក់ទងនឹងសៀវភៅដែលមានចំណងជើងថា *ប៉ុល ពត រៀបចំផែនការអនាគត* លោកជាអ្នកកែសម្រួលជាមួយនឹង បែន ឃានិន និង ប៊ូ ចាន់ធូ។ លោកបានអានគ្រប់ឯកសារដែលពាក់ព័ន្ធ។ សៀវភៅនេះបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៨៨។ ទាក់ទងនឹងសៀវភៅ *បងធំទីមួយ* លោកបានចាប់ផ្តើមការងារនៅចុងទសវត្សរ៍៨០ និងសរសេរនៅពេលដំណាលគ្នានឹងសៀវភៅ*សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា*។ សៀវភៅនេះបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៩២ កែសម្រួលនៅឆ្នាំ១៩៩៩ ដើម្បីបន្ថែមពីការស្លាប់របស់ ប៉ុល ពត។ ទាក់ទងនឹងសៀវភៅ *សម្លេងពីមន្ទីរស-២១* លោកបានចាប់ផ្តើមការងារនៅឆ្នាំ១៩៩៣ នៅទីក្រុងមេលប៊ិន នៅពេលដែលលោកទទួលយកបានចម្លើយសារភាពពីច្បាប់ចម្លងមៃក្រូហ្វីល។ ចំណុចខ្លះលោកបានធ្វើការនៅសហរដ្ឋអាមេរិក និងកម្ពុជា បោះពុម្ពផ្សាយនៅឆ្នាំ១៩៩៩។ ឯកសារជាភាសាខ្មែរដែលយកមកសរសេរសៀវភៅនេះគឺបានមកពីមជ្ឈ-មណ្ឌលឯកសារកម្ពុជា ឬមន្ទីរសន្តិសុខស-២១របស់ខ្មែរក្រហម។ លោកមិនបានពិនិត្យលើគ្រប់ចម្លើយសារភាពទាំង៤០០០នោះទេ ប៉ុន្តែលោកបានធ្វើបទសម្ភាសនិងសិក្សាទៅលើប្រតិចារិកនៃបទសម្ភាសជាមួយជនរងគ្រោះ និងអ្នកយាមនៅស-២១។ នៅក្នុងការស្រាវជ្រាវរបស់លោក លោកបានធ្វើកំណត់សម្គាល់ថា លោកមិនដែលសម្ភាសជនត្រូវចោទទាំងបីនោះទេ។

## ចៅក្រម ខាតវ៉ាយត៍ ពិនិត្យលើសាក្សី

នៅពេលប្រធាន និល ណុន សួរថាតើមានចៅក្រមណាចង់សួរសំណួរទៅសាក្សីទៀតទេ ចៅក្រម ខាតវ៉ាយត៍ បានស្ម័គ្រចិត្តសួរ ។ បន្ទាប់ពីពិនិត្យលើកម្រិតវប្បធម៌របស់លោក ឆេនដល័រ ចៅក្រម ខាតវ៉ាយត៍ បានពន្យល់ទៅកាន់សាក្សីអំពីចំណុចមួយចំនួនទាក់ទងនឹងសំណុំរឿង០០២ និង ភ័ស្តុតាងជាក់លាក់មួយចំនួនដែលមាននៅក្នុងសវនាការ ។

ចៅក្រម ខាត់វ៉ាយត៍ បានដំណើរទៅមុខដោយសួរសំណួរមួយចំនួនទាក់ទងនឹងសៀវភៅ ប៉ុល ពត រៀបចំផែនការអនាគត ដោយបង្ហាញពីចំណាប់អារម្មណ៍លើការពិនិត្យឯកសារដែលនៅសល់ពីរបបខ្មែរក្រហម ។ ទាក់ទងនឹងកថាមុខ ចៅក្រមបានបង្ហាញថានៅឆ្នាំ១៩៧៥-១៩៧៦ លោក ឆេនដល័រ បានសរសេរថាមាន«ទស្សនៈសុទិដ្ឋិនិយម ដើម្បីសម្រេចឲ្យបាននូវរបបសង្គមនិយមនៅកម្ពុជា ប៉ុន្តែបន្ទាប់ពីពេលនោះមក បក្សប្រែក្លាយទៅជាទុទិដ្ឋិនិយមជាងមុន កាចសាហាវ និងសម្ងាត់ ដោយសង្កត់ធ្ងន់ទៅលើការស្វែងរកសត្រូវ ។ ទាក់ទងនឹងថាតើសត្រូវជាអ្នកណា លោក ឆេនដល័រ បានឲ្យសក្ខីកម្មថាសត្រូវដំបូងគេ គឺអ្នកដែលមានជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ ឬទាហាន ។ បន្ទាប់មក លោកបានបកស្រាយថា «កំហឹងនេះបានរីករាលដាលដល់ប្រជាជនដែលធ្លាប់រស់នៅក្នុងរបបនោះ ដែលគេហៅថាប្រជាជនថ្មី ឬប្រជាជន១៧មេសា ។ លោកក៏បានរៀបរាប់ពីការឃើញ «ការពង្រីកសំណាញ់ដ៏ធំ»បន្ទាប់បើកគុកទួលស្លែង ដែលស្គាល់ជា ស-២១ នៅឆ្នាំ១៩៧៦ ដែលចាប់ផ្ដើមរួមបញ្ចូលទាំងសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។

លោក ឆេនដល័រ បានបន្តរៀបរាប់ពីចំណុចដែលចៅក្រម ខាត់វ៉ាយត៍ បានអានលោកយល់ថា ចំណុចសុទិដ្ឋិនិយមខ្ពស់នៅក្នុងរបបខ្មែរក្រហម បានរីករាលដាលពីឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៦ ។

ទាក់ទងនឹងការនិពន្ធឯកសារទាំងប្រាំបី លោកបានពិនិត្យទៅលើឯកសារ ប៉ុល ពត រៀបចំផែនការអនាគត សាក្សីបានបង្ហាញថាមិនមាននរណាម្នាក់ចុះហត្ថលេខាលើកំណត់ត្រាកិច្ចប្រជុំ ឬពាក្យសម្តីដូច្នេះវាមានលក្ខណៈមិនច្បាស់លាស់ ។ ទាក់ទងនឹងពាក្យសម្តីនៅខែធ្នូ លោកបាននិយាយថា វាជាពាក្យសម្តីរបស់ ប៉ុល ពត ឬ អៀង សារី ដែលថាមានតែប្រជាជនដែលមានឋានៈខ្ពស់ទេដែលអាចនិយាយបាន ។

ចៅក្រមខាតវ៉ាយបានពិនិត្យលើឯកសារមួយចំនួនជាមួយសាក្សី ៗ ទាក់ទងនឹងកំណត់ត្រាប្រជុំរបស់គណៈមជ្ឈិមនៅថ្ងៃទី៣០ខែមីនាឆ្នាំ១៩៧៦ លោក ឆេនដល័រ បាននិយាយថា ឯកសារនេះមិនត្រូវបានយកទៅចែកចាយដោយទូលាយទេ គឺមានតែឯកសារ១០-១៥ច្បាប់ដែលត្រូវបានរៀបចំ

ឡើងនៅពេលមានការប្រជុំម្តងៗ ។ លោកបានអានឯកសារនិងលើកឡើងពីចំណុចជាក់លាក់មួយ គឺ «សិទ្ធិកម្មេចអ្នកនៅក្នុងនិងអ្នកនៅក្រៅ» ដោយនិយាយថាវាអាចផ្តល់ជាសិទ្ធិមួយដល់គណៈភូមិភាគ និង ប្រជាជននៅក្នុងតំបន់ដំណើរការការងារបាន ។ លោកបានយល់ស្រប់ថាឯកសារនេះ បានរៀបរាប់ពី ផែនការរបស់បក្ស ។

ចៅក្រម ខាតវ៉ាយត៍ ក៏បានលើកឡើងពីកំណត់ត្រាប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលមិនមាននៅ ក្នុងសៀវភៅរបស់សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ។ ចៅក្រម ខាតវ៉ាយត៍បានលើកឡើងពីឯកសារ ដែលមានចំណងជើងថា«កំណត់ត្រាប្រជុំរបស់គណៈអចិន្ត្រៃយ៍ នៅថ្ងៃទី១១ខែមីនាឆ្នាំ១៩៧៦»ដែល មានឈ្មោះ នួន ជា, អៀង សារី និង ខៀវ សំផន ដែលជាអ្នកចូលរួម ។ ចៅក្រមបានសង្ខេបថា នៅក្នុងអង្គប្រជុំមានការពិភាក្សាទៅលើបញ្ហាជាមួយវៀតណាមទាក់ទងនឹងព្រំដែនខាងជើង ហើយអង្គការ ក៏បានផ្តល់យោបល់នៅក្នុងអង្គប្រជុំនោះដែរ ។ ឯកសារស្រដៀងគ្នាផ្សេងទៀតដែលកត់ត្រាការប្រជុំ របស់គណៈអចិន្ត្រៃយ៍ក៏ត្រូវបានយកមកពិភាក្សាដែរ ។ ចៅក្រម ខាតវ៉ាយត៍ បានសួរថា «នៅក្នុង បរិបទអង្គប្រជុំ តើពាក្យអង្គការសំដៅលើ ប៉ុល ពត ឬក៏វាមានន័យធំជាងនេះគឺរួមទាំងសមាជិកបក្ស កុម្មុយនីស្តកម្ពុជាផងដែរ?» សាក្សីបានបង្ហាញថាវាអាចសំដៅលើ ប៉ុល ពត ឬក៏អង្គការជារួម ។ លោកបាននិយាយថាប៉ុន្តែ «ខ្ញុំមិនមានភស្តុតាងដោយផ្ទាល់ដើម្បីបញ្ជាក់ទេ នេះគ្រាន់តែជាការសន្និត របស់ខ្ញុំ» ។

បន្ទាប់មកចៅក្រម ខាតវ៉ាយត៍ បានពិនិត្យលើកំណត់ត្រាប្រជុំរបស់គណៈអចិន្ត្រៃយ៍ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ១៩៧៦ ដែលលើកឡើងថាការប្រជុំដឹកនាំដោយ នួន ជា និងចូលរួមដោយ ខៀវ សំផន ។ នៅពេលនោះ យ៉ា បានផ្តល់របាយការណ៍ដ៏ច្បាស់លាស់ទាក់ទងនឹងកិច្ចចរចាជាមួយវៀតណាម លើបញ្ហាព្រំដែនខាងជើង ។ ដូចដែលបានបង្ហាញដោយចៅក្រម ខាតវ៉ាយត៍ នៅក្នុងកំណត់ត្រាប្រជុំ នោះ នួន ជា ដែលជាអនុលេខាបក្សក៏បានផ្តល់សេចក្តីណែនាំនិងយោបល់ ដែលរួមមានបញ្ជាឲ្យប្រើ គ្រាប់បែក និងពន្លិចទូកវៀតណាម ។ សាក្សីបាននិយាយថាកំណត់ត្រាប្រជុំជាមួយ នួន ជា មាន លក្ខណៈផ្ទុយខុស ពីអ្វីដែល នួន ជា វាយតម្លៃខ្លួនឯងថាជាអ្នកនយោបាយ ដែលមានអំណាចតិចនៅ ក្នុងយោធា ។

ចំពោះដីកាដំណោះស្រាយ ចៅក្រម ខាតវ៉ាយត៍ បានធ្វើកំណត់សម្គាល់ថា សហចៅក្រម ស៊ើបអង្កេតបានកំណត់មនុស្ស៨នាក់នៅក្នុងបក្សកម្ពុជាប្រជាធិបតេយ្យ ។ លោក ឆេនដល័រ បានអះ អាងថា គោលនយោបាយទាំងនេះតំណាងឲ្យគោលនយោបាយសំខាន់ជាងនេះនៅក្នុងបក្ស និងលើក ឡើងពីចំណុចសំខាន់ជាងគេបី ទោះបីជាចំណុចទីបួន និងទីប្រាំ ក៏មានសារសំខាន់ដែរ ។ លោកបានរៀប

រាប់ពីចលនារបស់ប្រជាជនថាជាគោលនយោបាយជាតិ និងធ្វើកំណត់សម្គាល់ថាគោលនយោបាយ «តាមដានរកធាតុផ្សំអាក្រក់» មានរូបរាងទៅហើយ ប៉ុន្តែវាត្រូវបានគេយកមកអនុវត្តនៅពេលដែលអ្នកដែលធ្លាប់ធ្វើការឲ្យ លន់ នល់ ត្រូវបានគេរកឃើញ ។ លោកបាននិយាយថា «ប្រសិនបើអ្នកទាំងនោះត្រូវបានសម្លាប់ជាប្រព័ន្ធ» ខ្មែរក្រហមប្រហែលជាបានដាក់គោលដៅលើវៀតណាមតាំងពីដំបូង ប៉ុន្តែមិនទាន់បានដាក់គោលដៅលើចាមទេ ។ ជាសរុប លោកបាននិយាយថាគោលនយោបាយដំបូងពីរ កើតឡើងមុនឆ្នាំ១៩៧៥ គោលនយោបាយទីបីចាប់ផ្តើមមានប្រសិទ្ធភាពនៅពេលដែលខ្មែរក្រហមទទួលបានជ័យជំនះនៅភ្នំពេញ ។ គោលនយោបាយទីបួន និងទីប្រាំកើតមានបន្ទាប់ដោយមានការកំណត់គោលដៅលើវៀតណាម ដែលបានកើតឡើងបន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ ។

លោក ឆេនដន័រ បានពន្យល់ថា គោលនយោបាយខ្លះទាំងនេះត្រូវបានយកមកបកស្រាយពន្យល់នៅពេលប្រជុំជាមួយស្រុក តំបន់ និងភូមិភាគ ហើយមានតែសមាជិកបក្សមានកំណត់ដែលអាចទទួលបានទស្សនាវដ្ដី ទង់បដិវត្ត។ បន្ទាប់មក ចៅក្រម ខាតវ៉ាយត៍ បានធ្វើសេចក្ដីសង្ខេបលើបញ្ហា ។

## សហព្រះរាជអាជ្ញាជាតិចាប់ផ្តើមសួរសំណួរសាក្សី

ជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា ចាន់ តារាវស្នី ចាប់ផ្តើមសួរសំណួរទាក់ទងនឹងកម្រិតវប្បធម៌របស់ លោក ឆេនដល័រ ។ សាក្សីបានរៀបរាប់ពីកម្រិតវប្បធម៌របស់លោកម្តងទៀត ហើយបន្ទាប់រៀបរាប់ពីសៀវភៅដែលលោកបានបោះពុម្ព ។

ដំបូង ព្រះរាជអាជ្ញាបានសុំការអះអាងបញ្ជាក់ម្តងទៀតពី លោក ឆេដន័រ អំពីប្រភពស្រាវជ្រាវដែលលោកបានផ្តោតទៅលើ ។ សាស្ត្រាចារ្យ ឆេនដល័រ សៀវភៅនីមួយៗរបស់លោកផ្អែកលើប្រភពផ្សេងគ្នា ។ សៀវភៅ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៨៣ ផ្អែកទៅលើបណ្ណសារដ្ឋានបារាំង ថៃ និងអាមេរិក ។ ទាក់ទងនឹងសៀវភៅទីពីរដែលមានចំណងជើងថា ប៉ុល ពត រៀបចំផែនការអនាគត ការស្រាវជ្រាវធំរបស់លោកគឺផ្អែកទៅលើឯកសារនោះ ។ សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ដែលជាសៀវភៅវែងជាងគេរបស់លោកផ្អែកលើបណ្ណសារដ្ឋានជាច្រើន ដូចជាបណ្ណសារដ្ឋាននៅបារាំង អាមេរិក អូស្ត្រាលី និងចក្រភពអង់គ្លេស និងផ្អែកទៅលើប្រភពទីពីរគឺការឆ្លើយតបរបស់អ្នកការទូតអាមេរិក និងបទសម្ភាសន៍ជាមួយអ្នកដែលធ្លាប់ឆ្លងកាត់រយៈកាល ឆ្នាំ ១៩៧៥-១៩៧៩ ជាង១០០នាក់ ។ ចំពោះសៀវភៅ បងធំទីមួយ ដែលលោកបានសរសេរនៅពេលជាមួយគ្នា លោកផ្តោតលើប្រភពដូចគ្នា ប៉ុន្តែលោកក៏បានធ្វើបទសម្ភាសន៍ជាមួយអ្នកផ្សេងទៀត

ដែលស្គាល់ និងពាក់ព័ន្ធជាមួយ ប៉ុល ពត ។ នៅក្នុងសៀវភៅ នៅក្រោយជញ្ជាំងមន្ទីរស-២១ ប្រភពសំខាន់គឺឯកសារមកពីមន្ទីរស-២១ អតីតបុគ្គលិក អ្នកដែលនៅរស់ និងពីបទសម្ភាសន៍ដែលគេធ្លាប់ធ្វើ ។ លោកក៏បានមើលទៅលើប្រភពទីពីរដើម្បីស្វែង យល់ពីសភាពនៃរបបដែលមានមនុស្សស្លាប់ជាច្រើនដែលរួមមានសៀវភៅដែលនិយាយអំពី ហូឡូកូស៍ និងការកែទម្រង់របស់ ស្តាលីន នៅប្រទេសយូក្រែន ។

លោក ចាន់ តារាស្មី បានសួរលោក ឆេនដល័រ នៅក្នុងចំណោមសៀវភៅដែលលោកបានសរសេរ តើលោកបានសម្ភាសជាមួយជនភៀសខ្លួននៅជំរុំខាវអ៊ីដាង នៅប្រទេសថៃដែរឬទេ? លោក ឆេនដល័រ បានបង្ហាញថា នៅឆ្នាំ១៩៨៤ លោកបានសម្ភាសជនភៀសខ្លួនកម្ពុជា ដែលតាមឯកសារខ្លះបង្ហាញថាអ្នកទាំងនោះធ្លាប់ជាខ្មែរក្រហម ដូច្នេះមិនអាចបញ្ជូនទៅប្រទេសទីបីបានទេ ។ លោកបានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងចំណោមបទសម្ភាសជាមួយជនភៀសខ្លួន៣០០-៤០០នាក់ លោកបានព្យាយាមសួរពីឋានៈ និងប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ ។

ដោយបង្ហាញពីការស្រាវជ្រាវអំពីបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ លោក ឆេនដល័រ បាននិយាយថាលោកបានព្យាយាមបង្កើតលំហូរនៃព្រឹត្តិការណ៍នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចយ៉ាងសុក្រិត ។ លោកបានធ្វើ«កំណត់សម្គាល់ផ្ទាល់ខ្លួនថា» លោកប្រាកដជាសប្បាយចិត្តណាស់ ប្រសិនបើលោកមានព័ត៌មាននៅក្នុងដីកាដំណោះស្រាយ នៅពេលដែលលោកសរសេរសៀវភៅរបស់លោកនៅទសវត្សរ៍៨០ ។ លោកបានរៀបរាប់ថាលោកបានព្យាយាមអស់ពីសមត្ថភាពដើម្បីស្រាវជ្រាវ ពីគោលដៅនៃការស្រាវជ្រាវពីអ្វីដែលបានកើតឡើងនៅពេលនោះ ជីវិតរបស់បុរសម្នាក់ ឬដំណើររបស់ស្ថាប័នមួយ ។

លោក ឆេនដល័រ បានបន្តបកស្រាយពន្យល់ពីប្រវត្តិរបស់លោកថា លោកបានចាប់ផ្តើមសិក្សាអំពីខ្មែរក្រហម និងបក្សកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៥ និង១៩៧៦ ។ លោកបានបកស្រាយថា នៅពេលដែលលោកមានភាពច្របូកច្របល់ និងមិនសូវច្បាស់អំពីអ្វីដែលបានកើតឡើងនៅកម្ពុជា លោកបានធ្វើបទសម្ភាសជាមួយជនភៀសខ្លួនមួយចំនួនបានមករស់នៅប្រទេសអូស្ត្រាលី ហើយបន្ទាប់មក លោកបានសរសេរ«អត្ថបទមួយ» ។ លោកបានរំពឹកថាចំណាប់អារម្មណ៍បានចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៧៥ ប្រសិនបើមិនដូច្នោះគឺតាំងពីពេលដែលលោកធ្វើការស្រាវជ្រាវសម្រាប់សរសេរសៀវភៅរបស់លោកដើមទសវត្សរ៍៨០ ហើយពីឆ្នាំ១៩៨១ ការស្រាវជ្រាវរបស់លោកទាំងអស់គឺផ្តោតទៅលើរយៈកាលនៃរបបខ្មែរក្រហម ។

## *សហព្រះរាជអាជ្ញាសួរសាក្សីអំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា*

*លោក ចាន់ បានប្តូរប្រធានបទថ្មីមួយទៀត គឺលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ដេវីដ ឆេនដល័រ មិនចាំថាតើគាត់បានអានលក្ខន្តិកៈនោះពីមុនដែរឬទេ លោកប្រហែលជាបានខ្លះ ប៉ុន្តែលោកមិនចាំច្បាស់ទេ ។ បន្ទាប់ពីមើលលក្ខន្តិកៈដែលដាក់នៅពីមុខគាត់ គាត់បានផ្តល់សក្ខីកម្មថា គាត់យល់ថាចំណុចនេះមានបំណងបង្កើតគំនិត និងគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជាអ្នកគ្រប់គ្រងកុម្មុយនីស្តកម្ពុជា និងជាឧបករណ៍សម្រាប់បដិវត្តន៍កម្ពុជា ។ លោកមិនដឹងថាលក្ខន្តិកៈនេះត្រូវបានសរសេរឡើងនៅពេលណាទេ ។*

*បន្ទាប់មក លោក ចាន់ ដកស្រង់កថាខណ្ឌទីពីរនៃលក្ខន្តិកៈ ប៉ុន្តែនៅពេលដែលលោកសួរសាក្សីថាតើលោកបានអានកថាខណ្ឌនោះទេ មេធាវីការពារក្តី អៀង សារី លោក ឧត្តម បានស្នើសុំនិយាយ ។ មុនពេលអនុញ្ញាតឲ្យលោកនិយាយ លោកប្រធាន និល ណុន បានសួរលោក ឆេនដល័រ ឆ្លើយនឹងសំណួររបស់ព្រះរាជអាជ្ញាជាមុនសិន ។ លោក ឆេនដល័រ ឆ្លើយថា លោកធ្លាប់បានអាចឯកសារនោះ ។*

*លោក ឧត្តម បានលើកឡើងអំពីកំណត់សម្គាល់ពីមុនរបស់លោក ឆេនដល័រ ថា លោកមិនដែលបានឃើញលក្ខន្តិកៈនោះទេ. លោកបានស្នើឲ្យអង្គជំនុំជម្រះដកឯកសារដែលផ្តល់ឲ្យដោយផ្ទាល់ដល់សាក្សី ។*

*លោកប្រធាន និល ណុន បានអរគុណដល់ការអង្កេតរបស់លោក ឧត្តម ប៉ុន្តែបន្ថែមថា មេធាវីការពារក្តីប្រហែលជាមានកំហុស ។ លោកចៅក្រមបានបកស្រាយថា លោក ឆេនដល័រ ប្រហែលជាអានលក្ខន្តិកៈទាំងអស់ ដែលមិនមាននៅក្នុងសំណុំរឿង ។*

*លោក ចាន់ បានបន្តសួរសាក្សីនូវពាក្យមួយចំនួនដែលមាននៅក្នុងលក្ខន្តិកៈ ។ លោកបានសួរអំពីអត្ថន័យនៃឃ្លា«បក្សបានបន្តដឹកនាំបដិវត្តន៍សង្គមនិយម និងបង្កើតលទ្ធិសង្គមនិយមដោយផ្អែកលើអំណាចផ្តាច់ការ ហើយភាពដើមនៃបក្សគឺរចនាសម្ព័ន្ធខ្ពស់ជាងគេនៅក្នុងវណ្ណៈកម្មករ និងជាមេបញ្ជាការមើលការខុសត្រូវនិងគ្រប់គ្រងលើការងារបដិវត្តន៍» ។ សាក្សីបានពន្យល់ថាវាគឺជា«ឃ្លាដែលមានន័យច្បាស់ គឺថាតួនាទីរបស់អ្នកដឹកនាំមិនត្រឹមតែស្របច្បាប់ទេ ប៉ុន្តែថែមទាំងផ្តាច់ការ ។ នេះគឺជាអំណាចតែមួយគត់ដែលត្រូវបានអនុញ្ញាតឲ្យមានវត្តមាននៅប្រទេសកម្ពុជា» ។*

*លោក ឆេនដល័រ បាននិយាយថាពាក្យ«អំណាចផ្តាច់ការ» មិនត្រឹមតែមានន័យជាអំណាចផ្តាច់ការនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែក៏ជាការរិតត្បិតលើព័ត៌មានមិនឲ្យចេញទៅក្រៅដែរ ។ លោកបានបកស្រាយពាក្យនេះថាបក្សកុម្មុយនីស្តកម្ពុជាចាប់ពីពេលនោះទៅគឺជា«ខ្យល់ដែលប្រជាជនស្រូបយក» ។*

ទាក់ទងនឹងអត្ថន័យនៃឃ្លា«ការគ្រប់គ្រងដ៏ខ្ពស់បំផុត» លោក ឆេនដល័រ បានឲ្យនិយមន័យថា វាប្រៀបដូចនឹងពាក្យថា«យើងជាអ្នកទទួលខុសត្រូវ» ។

បន្ទាប់មក លោក ចាន់ បានសួរឲ្យមានការបកស្រាយពន្យល់អំពីតួនាទីរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោក ឆេនដល័រ បានឆ្លើយតបថា «ខ្ញុំសង្ឃឹមថា ខ្ញុំអាចឆ្លើយបាន» ។ លោកបានបន្តថា អ្នកដែលសរសេរឯកសារគិតថាបក្សនឹងរឹងមាំ និងច្បាស់លាស់ ។ លោកបានធ្វើកំណត់សម្គាល់ថា «ខ្ញុំមិនគិតថាមានបក្សណាមួយអាចអនុវត្តដូចដែលឯកសារនេះបានរៀបរាប់ទេ» ។ ចំពោះសំណួរថាតើវាដំណើរការដោយរបៀបណាដែរ លោក ឆេនដល័រ បាននិយាយថា ប្រសិនបើមើលតាមប្រវត្តិសាស្រ្តនៃរបបកម្ពុជាប្រជាធិបតេយ្យ គ្មាននរណាម្នាក់អាចកំណត់ចម្លើយច្បាស់បានទេ ។

ជាបន្ត លោក ចាន់ បានលើកឡើងពីពាក្យ«មជ្ឈការប្រជាធិបតេយ្យ»នៅក្នុងកថាខណ្ឌទី៦ ដើម្បីចង់ដឹងពីការយល់ឃើញរបស់លោក ឆេនដល័រ ទៅលើពាក្យនេះ ។ លោក ឆេនដល័រ បានឆ្លើយថាវាហាក់ដូចជាមានលក្ខណៈផ្ទុយពីពាក្យដែលថា «មិនមានប្រជាធិបតេយ្យនៅក្នុងការគ្រប់គ្រងបែបមជ្ឈការរបស់បក្ស» ។ លោកបានធ្វើកំណត់សម្គាល់ថា «បក្សចាត់ទុកខ្លួនឯងថាជាអ្នកបង្កើតឆន្ទៈដល់ប្រជាជន... ។ បក្សគិតថាអាជ្ញាធរមជ្ឈការលគឺជាអ្នកតំណាងឲ្យប្រជាជន» ។ លោកបានបន្ថែមទៀតថា នេះហាក់ដូចជាមិនសមហេតុសមផលប៉ុន្មានទេ ហើយបានបន្តទៀតថា ខ្មែរក្រហម«យល់ថាខ្លួនគឺជាអ្នកតំណាងប្រជាធិបតេយ្យស្របច្បាប់ នេះគឺជាអំណាចបែបមជ្ឈការរបស់ប្រជាជន» ។ បន្ទាប់មក លោក បានទទួលស្គាល់ថាវាគឺជាពាក្យដែលពិបាកបកស្រាយ ។

លោក ខាណារ៉ាស មានការជំទាស់ដោយអះអាងថាបញ្ហាមួយចំនួនដែលសួរទៅសាក្សីគឺដើម្បីចង់បានទស្សនៈផ្លូវច្បាប់ ប៉ុន្តែមានតែសាក្សីជំនាញតែប៉ុណ្ណោះដែលអាចមានសិទ្ធិឆ្លើយបាន ។ លោក បានស្នើរឲ្យលោក ឆេនដល័រ ផ្តល់ចម្លើយទាក់ទងនឹងការយល់ដឹងរបស់លោកទៅលើការស្រាវជ្រាវរបស់លោក ឬស្នើឲ្យមានការចោទជាសំណួរម្តងទៀត ។ ដើម្បីជាការឆ្លើយតប លោកប្រធាន និល ណុន បានស្នើឲ្យលោក ចាន់ រៀបចំសំណួរសម្រាប់សួរម្តងទៀត ។ លោកបានអះអាងថា តុលាការប្រហែលជាមិនអាចជួយកោះហៅអ្នកប្រវត្តិសាស្រ្តឲ្យមកបកស្រាយពន្យល់ទៅលើគ្រប់ពាក្យបច្ចេកទេសទេ លោកបានរំឭកដល់ភាគីថាសំណួរគួរតែមានលក្ខណៈ«សាមញ្ញនិងអាចជាប់ពាក់ព័ន្ធនឹងរឿងរ៉ាវនៅស-២១ ឬករណីទាំងមូលរបស់សំណុំរឿង ០០២» ។ លោកប្រធាន និល ណុន បានបន្ទរាក់លោក ចាន់ នៅពេលដែលគាត់និយាយពាក្យអរគុណ ដោយសង្កត់ធ្ងន់ម្តងទៀតថា «យើងមិនមែនសួរសាក្សីឲ្យបកស្រាយពីពាក្យបច្ចេកទេសទេ» ។

ជាបន្ត លោក ចាន់ បានលើកឡើងពីមាត្រា៣នៃលក្ខន្តិកៈដោយសួរបន្ថែមអំពីមជ្ឈការប្រជាធិបតេយ្យ ។ ខណៈពេលដែលលោក ឆេនដល័រ បានធ្វើកំណត់សម្គាល់ថាលោកមិនមែនជាទស្សនវិទូនយោបាយ លោកបាននិយាយថា“សមាជិកអាចពិភាក្សាអំពីកិច្ចការងាររបស់បក្ស បើយោងទៅតាមបទបញ្ញត្តិ និងសំណើមកពីថ្នាក់លើ” ។ លោកបានរៀបរាប់ថា មានតែសមាជិកបក្សទេដែលមានសិទ្ធិនិយាយអំពីកិច្ចការរបស់បក្ស ។ លោកក៏បានរៀបរាប់ថាតើអ្នកនៅថ្នាក់ក្រោមអាចធ្វើការពិភាក្សាបានដោយរបៀបណា ប៉ុន្តែប្រសិនបើមានការផ្លាស់ប្តូរពីថ្នាក់លើ គឺត្រូវគោរពតាមច្បាប់ ។ ប្រសិនបើការពិភាក្សានៅថ្នាក់ក្រោមត្រូវបានទាត់ចោល នោះអ្នកទាំងនោះត្រូវតែគោរពតាម ។ ដើម្បីបញ្ជាក់ការបកស្រាយឲ្យកាន់តែច្បាស់ លោកបានលើកឡើងពីរឿងកំប្លែងនៅប្រទេសឆេកូស្លូវ៉ាគី ដើម្បីឲ្យអ្នកនៅក្នុងបន្ទប់សវនាការសើច ។ មានកូនម្នាក់បានសួរទៅឪពុកថាអ្វីទៅជាមជ្ឈការប្រជាធិបតេយ្យ ឪពុកក៏ឆ្លើយថា “ពុកនឹងប្រាប់កូនទៅពានហាលមុខផ្ទះយើង ហើយឈរនៅទីនោះ ឪពុកក៏ប្រានកូនចេញពីផ្ទះ បន្ទាប់មកក៏និយាយថា “ឥឡូវនេះយើងបំបែកគ្នាហើយ” ។

លោក ខណាវ៉ាស បានជំទាស់ម្តងទៀតដោយអះអាងថា “ច្បាស់ណាស់ បុរសនេះមិនមានសមត្ថភាពនឹងពិភាក្សាអំពីឯកសារជាក់លាក់នេះទេ” ។ លោក ខណាវ៉ាស បានជំទាស់នឹងវិធីសាស្រ្តសួរសំណួរពីព្រោះសំណួរដែលសួរទៅលោក ឆេនដល័រ គឺជាការស្នើឲ្យមានការបកស្រាយបែបច្បាប់ ។ លោកបានធ្វើសេចក្តីសន្និដ្ឋានថា“សំណួរដែលសួរហាក់ដូចជាសម្រាប់សួរទៅអ្នកជំនាញផ្នែកច្បាប់អ្វីដែលលោកបាននិយាយគឺជាការសន្មតទាំងអស់ ហើយចំពោះរឿងនៅប្រទេសឆេកូស្លូវ៉ាគី ខ្ញុំមិនខ្វល់ទេ” ។

បន្ទាប់ពីព្កការឆ្លើយតបរបស់ជំនួយការជាន់ខ្ពស់របស់ព្រះរាជអាជ្ញា ថារីក អាប់ឌុលហាក់ លោកប្រធាន និល ណុន បានធ្វើកំណត់សម្គាល់លើ“ការអង្កេត”របស់លោក ខណាវ៉ាស បន្ទាប់មកស្នើឲ្យព្រះរាជអាជ្ញារៀបចំសំណួរម្តងទៀតដើម្បីឲ្យស្របនឹងជំនាញរបស់លោក ឆេនដល័រ ។ លោកក៏បានធ្វើកំណត់សម្គាល់ថែមទៀតថា ការជំទាស់របស់លោក ខណាវ៉ាស មានលក្ខណៈមិនសមរម្យទេពីព្រោះរាល់ការជំទាស់គួរតែត្រូវធ្វើឡើងមុនពេលដែលសាក្សីឆ្លើយតបនឹងសំណួរ ។

មុនពេលដែលតុលាការសម្រាកបរិភោគអាហារពេលថ្ងៃ សហមេធាវីការពារក្តីអន្តរជាតិ នួន ជា គឺលោក ហ្សាស្ពើ ប៉ៅ បានស្នើថា ដោយសារបញ្ហាសុខភាព នួន ជា ស្នើសុំនៅសង្កេតមើលដំណើរការនីតិវិធីនៅក្នុងបន្ទប់ឃុំឃាំងនៅពេលសវនាការនៅពេលថ្ងៃ ។ បន្ទាប់ពីយល់ស្របនឹងសំណើលោក នួន ជា បានបក់ដៃលានៅក្នុងបន្ទប់សវនាការនៅពេលដែលអង្គជំនុំជម្រះអនុញ្ញាតលើសំណើរបស់លោក ។

## *លោក ចាន់ បន្តពិនិត្យលើសាក្សីដោយមានការជំទាស់ជាច្រើន*

បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ លោក ចាន់ បានបន្តសួរលោក ឆេនដល័រ ទាក់ទងនឹងលក្ខន្តិកៈរបស់បក្ស ។ លោក ចាន់ បានយោងទៅតាមមាត្រា៣ទាក់ទងនឹងសិទ្ធិរបស់សមាជិកក្នុងការពិចារណា និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើកិច្ចការរបស់បក្ស និងមាត្រា៦ទាក់ទងនឹងមជ្ឈការប្រជាធិបតេយ្យ ។ លោក ចាន់ បានសួរថាតើគោលការណ៍នៅក្នុងនោះឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងរបស់បក្សដែរឬទេ ។

មុនពេលសាក្សីអាចឆ្លើយនឹងសំណួរ លោក និល ណុន បានយល់ស្របនឹងលោក ខាណាវ៉ាស ដែលជំទាស់នឹងការសាកសួររបស់ព្រះរាជអាជ្ញា ពីព្រោះមានសំណួរទាក់ទងនឹងមាត្រាជាច្រើន ប៉ុន្តែចម្លើយដែលចង់បានគឺត្រឹមតែត្រូវ ឬមិនត្រឹមត្រូវ ។ លោក ខាណាវ៉ាស ស្នើឲ្យព្រះរាជអាជ្ញា សួរម្តងមួយមាត្រាៗ ។ លោក និល ណុន មិនបានជំទាស់អ្វីទៀតទេ ហើយស្នើរសាក្សីនិយាយឲ្យយឺតជាងមុន ។

ដើម្បីជាការឆ្លើយតបនឹងសំណួររបស់លោក ចាន់ ថាតើគោលការណ៍ដែលមាននៅក្នុងមាត្រា៣ និងមាត្រា៦ ឆ្លុះបញ្ចាំងពីការអនុវត្តរបស់បក្សដែរឬទេ លោក ឆេនដល័រ បាននិយាយថា លោក“មិនឆ្លើយថាតើវាមានការអនុវត្តបែបនេះរាល់ឆ្នាំ និងគ្រប់ស្រុក” ។ លោកបានលើកឡើងថា យោងទៅតាមរបប អ្នកខ្លះដែលនៅថ្នាក់ក្រោមមិនបានគោរពតាមវិធាននេះទេដែលបណ្តាលឲ្យមានការយកទៅអប់រំម្តងទៀត និងការដាក់ទណ្ឌកម្ម ។ លោកបានធ្វើកំណត់សម្គាល់ទៀតថា “អ្វីដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងនោះគឺវាបង្ហាញពីទស្សនៈគ្រប់គ្រងរបស់បក្សកម្ពុជាប្រជាធិបតេយ្យដែលហៅថា ក្បាលម៉ាស៊ីន ។ ក្រុមគ្រប់គ្រងគឺជាអ្នកសម្រេចលើអ្វីគ្រប់យ៉ាង” ។ លោកបានសង្ខេបចម្លើយរបស់លោកថា “ខ្ញុំមិនអាចឆ្លើយនឹងសំណួរទាក់ទងនឹងការអនុវត្តជាក់ស្តែងទេ ។

បន្ទាប់មក លោក ចាន់ សួរអំពីរចនាសម្ព័ន្ធថ្នាក់លើនិងថ្នាក់ក្រោមនៅក្នុងមាត្រា៦ ចំណុច៤ ។ លោក ឆេនដល័រ បានបកស្រាយថាជា“រចនាសម្ព័ន្ធពីរ៉ាមីត”រហូតដល់ថ្នាក់កំពូល ។ លោកបញ្ជាក់ថាវាពិបាកនឹងនិយាយថារចនាសម្ព័ន្ធថ្នាក់ក្រោមមានសភាពធំដល់កម្រិតណា ហើយថាតើវាសំដៅលើភូមិភាគឬកងពល ។ លោកបានបញ្ជាក់បន្ថែមថា វាពិបាកនឹងបកស្រាយថា តើអ្វីជា“រចនាសម្ព័ន្ធថ្នាក់ក្រោម” ។ លោកបកស្រាយថារចនាសម្ព័ន្ធថ្នាក់លើបន្តរហូតដល់អ្នកធ្វើសេចក្តីសម្រេចឲ្យបក្ស ។

និយាយអំពីប្រធានបទនៃការគ្រប់គ្រងបក្សកុម្មុយនីស្តកម្ពុជា លោក ចាន់ បានលើកឡើងពីលក្ខណៈវិនិច្ឆ័យ១០ដើម្បីសម្គាល់ពីភាពជាសមាជិកដែលផ្អែកទៅលើលក្ខន្តិកៈ ។ លោកបានយោងទៅមាត្រា៥ កថាខណ្ឌ១,៣,៥,៧ និង៨ ។ បន្ទាប់ពីទទួលសំណួរអំពីលក្ខណៈវិនិច្ឆ័យ លោក ឆេនដល័រ

បានឆ្លើយថាវាតំណាងឲ្យអ្វីដែលបក្ស ឬអ្នកព្រាងលក្ខន្តិកៈរំពឹងចង់បាន ។ លោកបានបកស្រាយថា នៅពេលដែលយើងមើលបញ្ច្រាសគោលការណ៍ទាំងនេះ យើងអាចមើលឃើញថាបក្សប្រឆាំងនឹងការមិនគោរពតាមនឹងមាគ៌ាបក្សនៅក្នុងកថាខណ្ឌទី១ ការមិនគោរពតាមសាមគ្គីភាពរបស់បក្សនៅក្នុងកថាខណ្ឌទី៣និង៥ និងអ្វីដែលផ្ទុយពីគោលនយោបាយសម្ងាត់ ឬកងកម្លាំងប្រដាប់អាវុធនៅក្នុងកថាខណ្ឌទី៧ ។ លោក ឆេនដល័រ បានរៀបរាប់ពីលក្ខណៈវិនិច្ឆ័យថាជា«លក្ខណាមួយក្រុមក៏ត្រឹមត្រូវ ប៉ុន្តែមិនមានភាពច្បាស់លាស់» គឺថា «អ្នកដែលគោរពតាមលក្ខណាទាំងអស់នឹងមិនមានបញ្ហាអ្វីឡើយ ហើយអាចធ្វើការបានជាផ្លែផ្កានៅក្នុងបក្សកុម្មុយនីស្ត» ។ លោកបានបន្តថា «ប៉ុន្តែខ្ញុំសុំសង្កត់ថា សេចក្តីសម្រេចមិនមែនបានមកពីការសម្រេចដោយខ្លួនឯងទេ គឺមកពីអ្នកដទៃគឺមេដឹកនាំរួម» ។ លោកបានសង្កត់ធ្ងន់ថាលក្ខណៈវិនិច្ឆ័យមានលក្ខណៈបត់បែន ហើយប្រជាជនអាចនឹងទទួលការកាត់សេចក្តីដ៏ធ្ងន់ធ្ងរដោយមិនពិចារណាលើទំហំនៃទោសកំហុសទេ ។ លោកបានសរុបសេចក្តីថា «វាមានលក្ខណៈស្មុគស្មាញ» ។

លោក ចាន់ សួរលោក ឆេនដល័រ ចង់ដឹងថាតើលោកដឹងថាហេតុអ្វីបានជាឃ្លា«ជំហរបដិវត្តដ៏រឹងមាំដើម្បីបង្កើតនិងពិនិត្យមើលជីវប្រវត្តិផ្ទាល់ខ្លួន» និងឃ្លា«ជំហរបដិវត្តន៍ដ៏រឹងមាំលើវណ្ណៈត្រូវបានរួមបញ្ចូលនៅក្នុងលក្ខណៈវិនិច្ឆ័យនៃលក្ខន្តិកៈរបស់បក្ស ។ លោក ឆេនដល័រ បានផ្តល់សក្ខីកម្មថា ប្រជាជនអាច«ចូលក្នុងបក្ស» ប្រសិនបើអ្នកទាំងនោះដើរតាមបក្សដ៏ត្រឹមត្រូវរឹងមាំនិងស្មោះត្រង់ ។ សាក្សីបានបកស្រាយថាមុនពេលនឹងក្លាយជាសមាជិកបក្សវាតម្រូវឲ្យឆ្លងកាត់ដំណើរការវែង ប៉ុន្តែលក្ខណៈវិនិច្ឆ័យជាច្រើននេះគឺផ្អែកលើភាពជាក់ស្តែង ។ លោកបានសន្និដ្ឋានដោយសើចបន្តិចបន្តួចថា «នេះគឺជាសំណួរល្អ ប៉ុន្តែពិបាកនឹងឆ្លើយពីព្រោះខ្ញុំមិនដែលចូលរួមក្នុងកិច្ចប្រជុំទាំងនោះទេ» ។ លោក ចាន់ បានយោងទៅតាមមាត្រា៧ កថាខណ្ឌទី១នៃលក្ខន្តិកៈដើម្បីសួរអំពីឯកសារយោងរបស់វាទៅនឹង«សិក្ខាសាលាទូទៅ» ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ លោក ឆេនដល័រ បានផ្តល់សក្ខីកម្មថា លោកត្រូវការរំឭកការចងចាំរបស់លោក ប៉ុន្តែលោកបានបង្ហាញថា លោកមិនច្បាស់ថាមានសិក្ខាសាលាមួយទេ ។ លោក ចាន់ បានឆ្លើយតបថា លោកនឹងសួរសំណួរនេះម្តងទៀតនៅពេលដែលលោក ឆេនដល័រ នឹកឃើញ ។

ជាថ្មីម្តងទៀត ទាក់ទងនឹងមាត្រា៧ កថាខណ្ឌទី១ លោក ចាន់ បានផ្តោតទៅលើការគ្រប់គ្រងរបស់បក្ស និងគណៈមជ្ឈិម ។ នៅពេលដែលមានសំណួរសួរថាតើការអនុវត្តស្របទៅតាមមាត្រានេះទេ លោក ឆេនដល័រ បានឆ្លើយថាដោយសារតែខ្វះខាតកំណត់ត្រាប្រជុំរបស់គណៈមជ្ឈិម លោកមិនដឹងថាតើនេះគឺជាមធ្យោបាយនៃការធ្វើការងារនោះទេ ប៉ុន្តែលក្ខន្តិកៈនោះបានរៀបរាប់ពីវិធីដែលធ្វើការងារ ។

បន្ទាប់មក លោក ចាន់ បានលើកឡើងពីមាត្រា២៣នៃលក្ខន្តិកៈដែលរៀបរាប់ពីការងាររបស់គណៈមជ្ឈិម ។ នៅពេលដែលមានសំណួរថាតើការងារទាំងនេះស្របនឹងការអនុវត្តដែរឬទេ លោក

ឆេនដល័រ បានឆ្លើយតបថា «ខ្ញុំមិនមានចម្លើយនេះទេ» ប៉ុន្តែលោកបានបន្តថា «ខ្ញុំគិតថាមានការដើរតាមវិធានទាំងនេះស្ទើរតែទាំងអស់» ។ លោកបានរៀបរាប់ពីការយល់ឃើញរបស់លោកថា អង្គការដំណើរការទៅល្អ ដោយយោងទៅតាមដីកាដំណោះស្រាយ និងឯកសារផ្សេងៗដែលលោកធ្លាប់ បានឃើញ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកបានធ្វើសេចក្តីសន្និដ្ឋានថាទាក់ទងនឹងការអនុវត្ត លោកធ្លាប់ស្គាល់ប្រជាជនដែលធ្លាប់ជាខ្មែរក្រហម ប៉ុន្តែមិនមែននៅក្នុងរបបខ្មែរក្រហមទេ ដូច្នេះលោក«មិន» និយាយនៅពេលនេះទេ ។

លោក ខាណាវ៉ាស ជំទាស់ម្តងទៀតថា នៅពេលដែលសាក្សីឆ្លើយថាខ្លួនមិនអាចឆ្លើយនឹងសំណួរទេ សាក្សីគួរតែបញ្ចប់ចម្លើយនិងមិននិយាយពីអ្វីផ្សេងទៀត ។ ដោយទទួលស្គាល់ថាភាគីទាំងអស់ មិនមែនតវ៉ាក្តីនៅមុខគណៈវិនិច្ឆ័យទេ គឺនៅមុខចៅក្រមដែលនឹងយល់ពីភាពខុសគ្នា លោកបានស្នើឲ្យសាក្សីកុំនិយាយអ្វីផ្សេង «ពីព្រោះលោកនឹងនៅក្នុងសវនាការពេញមួយព្រឹក» ។

លោកប្រធាន និល ណុន បានអរគុណដល់មេធាវីការពារក្តីចំពោះ«ការអង្កេត» និងរំឭកដល់សាក្សីថាប្រសិនបើមិនចាំចម្លើយទេ លោកមិនចាំបាច់ឆ្លើយនឹងសំណួរទេ ។ លោកបានរំឭកដល់គ្រប់ភាគីឲ្យសួរសំណួរដែលសមរម្យ និងស្របទៅតាមពេលវេលាដែលមាន ។

បន្ទាប់មក ចៅក្រម ខាត់វ៉ាយត៍ បាននិយាយថា អង្គជំនុំជម្រះយល់ស្របនឹងការជំទាស់ ។ លោកស្រី បានពន្យល់ដល់សាស្ត្រាចារ្យថា ប្រសិនបើលោកយល់ថាខ្លួនមិនអាចឆ្លើយនឹងសំណួរទេ លោកគួរតែកុំឆ្លើយពីព្រោះយើងមិនអាចប្រើការវាបាន ។

បន្ទាប់ពីចៅក្រមបានបញ្ឈប់ពីបញ្ហានេះរួច សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរសំណួរដោយមានការរំឭកពីប្រធាន និល ណុន ថាឲ្យជ្រើសរើសសំណួរដែលពាក់ព័ន្ធជាងគេបំផុត ឬកែប្រែសម្រួលសំណួរដែលសាក្សីអាចផ្តល់ចម្លើយដ៏មានសារប្រយោជន៍ដល់ការយល់ដឹងពីការពិត ។

## សហព្រះរាជអាជ្ញាសួរលោក ឆេនដល័រ អំពីគណៈអចិន្ត្រៃយ៍

ចំពោះសំណួរបន្ត លោក ឆេនដល័រ បានបង្ហាញថាលោកមានភ័ស្តុតាងថាមានវត្តមានរបស់គណៈអចិន្ត្រៃយ៍នៅក្នុងការស្រាវជ្រាវរបស់លោក ។ លោកបានបកស្រាយថាតើគណៈអចិន្ត្រៃជួបគ្នាញឹកញាប់ជាងគណៈមជ្ឈិមដោយរបៀបណា មានក្រុមតូចជាងគណៈមជ្ឈិមដោយរបៀបណា និងមានសមាជិកដូចគ្នាដោយរបៀបណា ។

បន្ទាប់មក លោក ចាន់ សួរសំណួរ«ដោយផ្អែកលើការស្រាវជ្រាវរបស់លោក តើលោកមានដឹងទេថាតើគណៈមួយណា ឬផ្នែកគ្រប់គ្រងមួយណាដែលអាចសម្រេចលើបញ្ហា ដូចជាបញ្ហាហិរញ្ញវត្ថុ

ឬកិច្ចការបរទេស ឬកិច្ចការពាណិជ្ជកម្ម? ឬតើគណៈមួយណាទទួលខុសត្រូវគ្រប់គ្រងកិច្ចការងារសង្គម និងការងារផ្សេងទៀត?

មុននឹងសាក្សីឆ្លើយសំណួរ លោក ខាណាវ៉ាស់ ជំទាស់ម្តងទៀតទៅលើបញ្ហាបច្ចេកទេស ។ លោក ខាណាវ៉ាស ជំទាស់ថាសំណួររបស់សហព្រះរាជអាជ្ញាសន្មតថាពិតជាមានវត្តមានរបស់គណៈកម្មការរួចទៅហើយ ។ លោក ខាណាវ៉ាស អះអាងថា «លោកអាចគ្រវីក្បាលរបស់លោកគ្រប់ពេលវេលា» ប៉ុន្តែសំណួរនេះគឺសន្មតទៅលើអង្គហេតុមិនមែនភ័ស្តុតាងដែលបញ្ជាក់ថាគណកម្មាការត្រូវបានបង្កើតឡើងដើម្បីគោលដៅនេះ ។ ជាការឆ្លើយតប លោក ចាន់ បានអះអាងថា វាប្រហែលជាមានបញ្ហាបកប្រែ ពីព្រោះនោះមិនមែនជាសំណួរដែលលោកបានសួរទេ ។

បន្ទាប់មកចៅក្រម និល ណុន ណែនាំឲ្យសាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរចុងក្រោយនេះទេ ពីព្រោះសំណួរនេះមិនច្បាស់ទេ ។ បន្ទាប់មកលោកបានណែនាំឲ្យសហព្រះរាជអាជ្ញាសួរសំណួរបន្ទាប់និងរំឭកដល់សហព្រះរាជអាជ្ញានិងភាគីទាំងអស់ថា ពេលវេលាដែលបម្រុងទុកសម្រាប់សួរសាក្សីគឺ មាន «កំណត់» ។

## សហព្រះរាជអាជ្ញាសួរអំពីមន្ទីរ ៨៧០

សហព្រះរាជអាជ្ញាបានសួរអំពីមន្ទីរ ៨៧០ និងការិយាល័យនយោបាយ៨៧០ ដែលលោក ឆេនដល័រ បញ្ជាក់ថាវាគឺជាឈ្មោះលេខកូដដែលមាននៅក្នុងឯកសារ ។ ទាក់ទងនឹងតួនាទីរបស់មន្ទីរ លោក ឆេនដល័រ បានឆ្លើយថាតួនាទីតែងរបស់គណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ប៉ុល ពត និង នួន ជា តែងតែមានលក្ខណៈជាន់គ្នា ។ លោកបានបកស្រាយថាមន្ទីរ៨៧០ថាជាកន្លែងដំណើរការមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជាដែល«ដោះស្រាយគ្រប់បញ្ហា» ប៉ុន្តែលោកបាននិយាយថាមិនមានការបញ្ជាក់ពីតួនាទីនៅក្នុងលក្ខន្តិកៈទេ ដូច្នេះវា«មានលក្ខណៈមិនច្បាស់លាស់» ។

លោក ដេវីដ ឆេនដល័រ បានបន្តបកស្រាយថាលេខកូដមន្ទីរ៨៧០ត្រូវបានដាក់តាំងពីមុនថ្ងៃទី ១៧មេសា ឆ្នាំ១៩៧៥ ហើយឈ្មោះនេះ«ត្រូវបានយកទៅប្រើប្រាស់»នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីសំដៅទៅ ប៉ុល ពត ឬ ប៉ុល ពត និងក្រុមអ្នកនៅជិតគាត់ ។

ទាក់ទងនឹងសមាជិករបស់មន្ទីរ៨៧០ ដេវីដ ឆេនដល័រ បាននិយាយថា «ខ្ញុំមិនគិតថា អ្នកដឹងពីវាទេ ។ វាគឺលេខទំនាក់ទំនងហើយមិនដែលមានការកត់ត្រាពីវាទេ» ។ លោកបានបន្តទៀតថាសមាជិកមានតិចហើយសម្ងាត់ ។ នៅក្នុងការស្រាវជ្រាវរបស់លោក លោកមិនដែលរកឃើញឯកសារណាមួយ

បង្ហាញពីភាពជាសមាជិករបស់ អៀង សារី, ខៀវ សំផន ឬ នួន ជា ទេ។ ប៉ុន្តែលោកបានធ្វើកំណត់សង្កត់ធ្ងន់ថា «វាមិនមែនជាមន្ទីរដាក់របស់របរទេ» ។

## ការជំទាស់កាន់តែច្រើន

ដោយប្តូរប្រធានបទ លោក ចាន់ បានសួរពីការចាប់ខ្លួន សូវ វ៉ាស៊ី ហៅ ឌឿន នៅឆ្នាំ ១៩៧៥ ។ ទាក់ទងនឹងហេតុផលដែលថាហេតុអ្វីបានជា ឌឿន ត្រូវបានចាប់ខ្លួន លោក ឆេនដល័រ បាននិយាយថា «ខ្ញុំមិនមែនប៉ាន់ស្មានពីរឿងនេះហើយសរសេរនៅក្នុងទំព័រ៦៣ និង៦៤នៅក្នុងសៀវភៅខ្ញុំទេ។ ខ្ញុំបាននិយាយថាអ្នកទោសដែលបាននាំទៅ ស-២១ គឺជាអ្នកដែលមានឋានៈខ្ពស់ ហើយ ឌឿន ត្រូវបានជំនួសដោយ ខៀវ សំផន។ «លោកបាននិយាយថា លោកគិតថា ហេតុផលដែល ឌឿន ត្រូវបានចាប់ខ្លួនគឺដោយសារតែលោកមានទំនាក់ទំនងជាមួយ កុយ ធួន។

លោក ខាណាវ៉ាស់ បានជំទាស់ម្តងទៀតដោយនិយាយថា «ប្រសិនបើលោក ឆេនដល័រ និយាយថា ខ្ញុំគិតថា តើនេះមានន័យថាជាការស្មានរបស់លោកមែនទេ? ប្រសិនបើនេះជាការស្មាន លោកមិនគួរឆ្លើយនឹងសំណួរនេះទេ» ។ បន្ទាប់ពីលោក ខាណាវ៉ាស់ បញ្ចប់ការជំទាស់របស់លោក លោក ឆេនដល័រ បានបង្ហាញពីភាពមិនពេញចិត្ត ហើយសួរទៅវិញថាតើមាននរណាម្នាក់ដឹងច្បាស់ថាមានអ្វីកើតឡើងនៅស-២១ទេ? លោកបានបកស្រាយថា លោកបានប្រើប្រាស់ឯកសារដើម្បីជាភស្តុតាងដល់អ្វីដែលលោកគិតថាបានកើតឡើង ។ «អ្វីដែលខ្ញុំអាចធ្វើបានគឺគិត» ហើយលោកបានធ្វើការសុំទោសប្រសិនបើការឆ្លើយបែបនេះមិនមានភាពគ្រប់គ្រាន់នោះ ។

ដើម្បីជាការឆ្លើយតប លោក ខាណាវ៉ាស់ បានលើកឡើងថា លោកមិនមែនស្នើឲ្យសាក្សីធ្វើអ្វីដែលគេមិនអាចធ្វើបានទេ ។ បន្ទាប់ពីសួរសំណួរមួយចំនួន លោក ខាណាវ៉ាស់ បានសួរថាតើសាក្សីដឹងពីចម្លើយដែរឬទេ ប្រសិនបើដឹង តើសាក្សីដឹងចម្លើយនោះដោយរបៀបណា និងផ្អែកទៅលើអ្វី? ប្រសិនបើមិនដឹងទេ ចម្លើយគួរតែជាពាក្យ«ខ្ញុំមិនដឹងទេ» និងមិនមានការស្មានអ្វីទៀតឡើយ ។ លោកបានធ្វើសេចក្តីសន្និដ្ឋានថា «យើងកំពុងតែនៅក្នុងតុលាការ មិនមែនសន្និសិទប្រវត្តិសាស្ត្រដែលយើងត្រូវស្មាននោះទេ» ។ បន្ទាប់ពីចៅក្រមបានពិភាក្សាគ្នា លោកប្រធាន និល ណុន អនុញ្ញាតឲ្យចៅក្រម ខាត់វ៉ាយត៍ ឆ្លើយតប ។

ចៅក្រម ខាត់វ៉ាយត៍ បានលើកឡើថា ការជំទាស់«ត្រូវបានអង្គជំនុំជម្រះទទួលស្គាល់ជាគោលការណ៍ ប៉ុន្តែប្រសិនបើអ្នកជំនាញនេះឆ្លើយនឹងសំណួរបានច្បាស់លាស់ និងផ្អែកទៅលើការស្រាវជ្រាវរបស់លោកនោះវាមិនមែនជាការស្មានទេ» ។ ទីពីរ លោកស្រីចៅក្រមបានបញ្ជាក់ពីបញ្ហាមួយចំនួនដែល

អ្នកជំនាញចាំបាច់ត្រូវតែដឹង «បញ្ហានៃការប្រើប្រាស់ការស្រាវជ្រាវដែលមានចម្លើយសារភាពមិនត្រូវបានទទួលស្គាល់ជាភ័ស្តុតាងនៅក្នុងតុលាការនេះ ក៏ដូចជាតុលាការផ្សេងទៀតដែរ» ។ លោកស្រីបានណែនាំសាក្សីថា «ប្រសិនបើសាក្សីនិយាយអំពីចម្លើយសារភាពនិងការស្រាវជ្រាវសាក្សីត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ដើម្បីអង្គជំនុំជម្រះថ្លឹងថ្លែងលើចម្លើយរបស់លោក» ។

ដើម្បីជាការឆ្លើយតប លោក ឆេនដល័រ បានអះអាងថា ការស្មានរបស់លោកគឺ ឌឿន ត្រូវបានចាប់ខ្លួនដោយមូលហេតុនេះ មិនមែនដោយសារតែ ឌឿន មានទំនាក់ទំនងជាមួយ កុយ ធួន ឬដោយសារតែ ឌឿន ត្រូវបានជំនួសដោយ ខៀវ សំផន ទេ ។

បន្ទាប់មក ចៅក្រម ខាត់រ៉ាយត៍ បានលើកឡើងម្តងទៀតពីសារសំខាន់ដែលថាសាក្សីចាំបាច់ត្រូវតែបញ្ជាក់ប្រាប់អង្គជំនុំជម្រះនៅពេលដែលសាក្សីប្រើប្រាស់ចម្លើយសារភាព ពីព្រោះអង្គជំនុំជម្រះមិនអាចពឹងផ្អែកលើចម្លើយសារភាពទេ ។

បន្ទាប់ពីសម្រាកពេលរសៀល លោក ចាន់ បានបន្តសួរសំណួរសាក្សី អំពី សឿ វ៉ាសុី ហៅ ឌឿន ។ លោក ឆេនដល័រ បានផ្តល់សក្ខីកម្មថា ខៀវ សំផន បានជំនួស សឿ វ៉ាសុី ហៅ ឌឿន បន្ទាប់ពីគាត់ត្រូវបានចាប់ខ្លួន ។ លោក ឆេនដល័រ បានឆ្លើយនឹងសំណួរដែលថាតើលោកសន្និដ្ឋានបែបនេះដោយរបៀបណាថា លោកត្រូវមើលលេខយោង៦៧នៅក្នុងសៀវភៅ ស-២១ របស់លោកសិន ប៉ុន្តែចំណុចនេះ«មិនមាននៅក្នុងចម្លើយសារភាព»ដូចដែលចៅក្រមបានរំឭកទេ ។

## សហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ សួរសំណួរសាក្សី

ជំនួយការសហព្រះរាជអាជ្ញាអន្តរជាតិជាន់ខ្ពស់ ថារីក អាប់ឌុលហាក់ បន្តធ្វើការត្រួតពិនិត្យសាក្សី ។ បន្ទាប់ពីបញ្ជាក់ថា លោក នឹងសួរបន្តពីសេរិកពីរបស់លោក លោកបានអានឃ្លាមួយចំនួននៅក្នុងសៀវភៅ សម្ដេងពីមន្ទីរស-២១ របស់លោក ឆេនដល័រ រៀបរាប់ពីមជ្ឈិមបក្ស ។ បន្ទាប់ពីមានការស្នើឲ្យបកស្រាយបន្ថែមពីពាក្យ «មជ្ឈិមបក្ស» លោក ឆេនដល័រ បាននិយាយថា ពាក្យនេះសំដៅទៅរកគណៈមជ្ឈិម ហើយក្បាលម៉ាស៊ីន គឺគ្រាន់តែជាឈ្មោះមួយទៀតសម្រាប់ហៅ ។ បន្ទាប់មក លោកបានធ្វើការកែសម្រួលពាក្យមួយចំនួនដែលសហព្រះរាជអាជ្ញាបានអានដោយថា ដោយយោងតាមព័ត៌មានពីការកាត់ក្តី ឌុច គឺ ឌុចជាអ្នកជាប់ទាក់ទងនឹង សុន សេន ដោយផ្ទាល់ និងទាក់ទងជាមួយ នួន ជា ម្តងម្កាល ។ ដោយហេតុនេះ មិនមានការបញ្ជាក់ច្បាស់លាស់អំពីទំនាក់ទំនងរបស់ ឌុច ជាមួយនឹងអ្នកផ្សេងទៀត និងមជ្ឈិមបក្សទេ ដូច្នេះព័ត៌មាននៅក្នុងសៀវភៅគឺ មិនត្រឹមត្រូវទេ ។

លោក ខាណាវ៉ាស់ បានសើចចំអកនឹងលោក ឆេនដល័រ និងជំទាស់ថា លោក ឆេនដល័រ កំពុងតែផ្តល់សក្ខីកម្មដោយផ្អែកលើភ័ស្តុតាងដែល ឌុច បាននិយាយនៅក្នុងសវនាការ និងផ្អែកទៅលើដីកាដំណោះស្រាយ គឺវាផ្ទុយពីអ្វីដែលលោកបានសិក្សាទាក់ទងនឹងការវិភាគឯកសារប្រវត្តិសាស្រ្ត ។ ដោយដឹងថា «យើងមិនអាចបញ្ឈប់សម្លេងកណ្តឹង និងលុបព័ត៌មាននោះនៅក្នុងខួរក្បាលរបស់លោកបានទេ» លោកបានស្នើថា អង្គជំនុំជម្រះអាចណែនាំសាក្សីឲ្យជូនដំណឹងដល់អង្គជំនុំជម្រះនៅពេលដែលលោកផ្អែកលើព័ត៌មានទាំងនោះ ។ ការធ្វើបែបនេះអាចធ្វើឲ្យយើងអាចឲ្យទម្ងន់ឬមិនឲ្យទម្ងន់លើសក្ខីកម្មរបស់លោក ។

លោក អាប់ឌុលហាក់ បានឆ្លើយតបថា នេះ«មិនមែនជាពេលវេលាដែលមេធាវីការពារក្តីត្រូវផ្តល់យោបល់លើគុណភាពនៃទស្សនៈរបស់អ្នកជំនាញទេ» ។ ទាក់ទងនឹងឯកសារយោងរបស់លោក ឆេនដល័រ ទៅនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០១ លោក អាប់ឌុលហាក់ បានអះអាងប្រឆាំងថា លោក ឆេនដល័រ បានព្យាយាមបញ្ជាក់ពីប្រភពដែលលោកបានយោងទៅហើយ ។ លោកបានធ្វើសេចក្តីសន្និដ្ឋានថា ការផ្តល់យោបល់ទាំងនេះពាក់ព័ន្ធនឹងការឲ្យទម្ងន់លើសក្ខីកម្មដែល ចៅក្រមនឹងធ្វើការវាយតម្លៃ ហើយដែលនឹងជាផ្នែកមួយនៃការពិនិត្យលើសាក្សី ប៉ុន្តែវាមិនមែនជាមូលដ្ឋានសម្រាប់ធ្វើការជំទាស់ទេ ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិនាំមុខ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត ផ្តល់យោបល់របស់លោកស្រីថា អ្នកជំនាញគួរតែបញ្ជាក់ឲ្យច្បាស់គ្រប់ពេលវេលានៅពេលដែលលោកឆ្លើយសំណួរដើម្បីបង្ហាញឲ្យច្បាស់ថា តើលោកផ្អែកលើអ្វីដែលលោកដឹងនៅពេលនោះ ឬផ្អែកទៅលើប្រភពបន្តបន្ទាប់ ។ ការធ្វើបែបនេះគឺដើម្បីបញ្ជាក់ឲ្យច្បាស់ ។

បន្ទាប់ពីពិភាក្សាគ្នាជាមួយចៅក្រមផ្សេងទៀត លោកប្រធាន និល ណុន ផ្តល់វេទិកាឲ្យចៅក្រម ខាត់រ៉ាយត៍ ។ លោកស្រីចៅក្រម ខាត់រ៉ាយត៍ បានអះអាងថាអង្គជំនុំជម្រះយល់ស្របថា សាក្សីអាចអានដីកាដំណោះស្រាយដែលជាឯកសារសាធារណៈ និងពិនិត្យលើសេចក្តីសន្និដ្ឋាននិងលើការស្រាវជ្រាវពីមុនរបស់លោកដើម្បីបញ្ជាក់ថាលោកត្រូវធ្វើការកែប្រែ លើការស្រាវជ្រាវរបស់លោកបន្ទាប់ពីបានអានដីការដំណោះស្រាយនេះ ។ ដូច្នេះអង្គជំនុំជម្រះមិនយល់ស្របនឹងការជំទាស់ ប៉ុន្តែស្នើឲ្យសាក្សី «បកស្រាយពន្យល់ថាតើលោកមានកែប្រែទស្សនៈរបស់លោកឬទេ បន្ទាប់ពីលោកបានអានដីកាដំណោះស្រាយ» ។ ចៅក្រម ខាត់រ៉ាយត៍ បានពន្យល់ថា «ការស្រាវជ្រាវជាច្រើនរបស់លោកមានរយៈពេលរាប់សិបឆ្នាំមកហើយ ហើយលោកអាចកែសម្រួលសេចក្តីសន្និដ្ឋានរបស់លោក ។ អង្គជំនុំជម្រះចង់ដឹងពីការឲ្យទម្ងន់របស់លោកទៅលើភ័ស្តុតាងហើយប្រភពនោះគឺជាអ្វី» ។

## លោក អាប់ ឌុលហាក់ សួរសាក្សីអំពីមជ្ឈិមបក្ស និងមន្ទីរ ៨៧០

លោក អាប់ ឌុលហាក់ បន្តសួរសាក្សីលោក ដេវីដឆេនដល័រ ថាតើនៅពេលបច្ចុប្បន្នលោកបានចាត់ទុកថាមជ្ឈិមបក្សមានរួមបញ្ចូល នួន ជា, អៀង សារិ និង ខៀវ សំផន ដែរឬទេ? លោក ឆេនដល័រ បានឆ្លើយថាមានរួមបញ្ចូលទាំងអ្នកផ្សេងទៀតផងដែរ ។ ទាក់ទងនឹងទំនាក់ទំនងរវាង ស-២១ និងមជ្ឈិមបក្ស លោក ឆេនដល័រ បាននិយាយថា លោកដឹងពី ឌុច ថា ឌុចមានទំនាក់ទំនងដោយផ្ទាល់នឹង សុន សេន ដែលជាគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ដូច្នេះ«អ្វីដែលទាក់ទងនឹង ស-២១ គឺគណៈមជ្ឈិមត្រូវតែដឹង» ។ លោកបកស្រាយថា ការផ្តល់យោបល់របស់អ្នកទាំងនោះគឺទាក់ទងនឹងកសិកម្ម វៀតណាម និងសត្រូវផ្ទៃក្នុង ។

ទាក់ទងនឹងសក្ខីកម្មពីមុនរបស់លោក ឆេនដល័រ ទាក់ទងនឹងរចនាសម្ព័ន្ធពីរ៉ាមីតរបស់មេដឹកនាំនៅកម្រិតកំពូល លោក អាប់ ឌុលហាក់ បានសួរថាតើលោក ឆេនដល័រ យល់ថា ស-២១ ស្ថិតនៅក្នុងផ្នែកណា? តើមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅផ្នែកណា? ដោយមានភាពភាន់ច្រឡំនឹងសំណួរ លោក ឆេនដល័រ បានឆ្លើយតបថា «វាមិនមែនជាផ្នែកណាមួយនៃមជ្ឈិមបក្សទេ... ឌុច មិនដែលចូលរួមក្នុងការប្រជុំទាំងនេះទេ ។ ឌុច មិនមែនជាគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ទេ...។ ឌុច មិនមានទំនាក់ទំនងជាមួយអ្នកទាំងនោះទេ» ។ នៅពេលមានសំណួរថាតើមានទំនាក់ទំនងរវាងមេដឹកនាំ និងអ្នកនៅក្រោមបង្គាប់ដែរឬទេ? លោក ឆេនដល័រ ឆ្លើយថា «នេះគឺជាមធ្យោបាយតែមួយតែអ្នកទាំងពីរក្រុមនេះទំនាក់ទំនងគ្នា ។ ឌុច គឺជាអ្នកនៅក្រោមបង្គាប់ ហើយ ឌុច អនុវត្តតួនាទីរបស់ខ្លួនយ៉ាងហ្មត់ចត់ និងប្រុងប្រយ័ត្ន» ។

ទាក់ទងនឹងសក្ខីកម្មពីមុនរបស់លោក ឆេនដល័រ ដែលថា ខៀវ សំផន ជំនួស ឌឿន លោក អាប់ឌុលហាក់ បានសួរអំពីតួនាទីដែល ខៀវ សំផន ធ្វើបន្ត។ លោក ឆេនដល័រ បានឆ្លើយថា ក្នុងនាមជាប្រធានមន្ទីរ ៨៧០ ខៀវ សំផន គួរតែទទួលតំណែងនេះ ប៉ុន្តែ ខៀវ សំផន មិនបានធ្វើការងារអ្វីបន្តពីនោះទេ។ លោក ឆេនដល័រ បានធ្វើសេចក្តីសន្និដ្ឋានថា លោកមិនអាចប៉ាន់ប្រមាណពីអ្វីដែល ខៀវ សំផន ត្រូវធ្វើ ហើយថា ការងារនោះផ្លាស់ប្តូរដោយរបៀបណាទេ។

នៅពេលដែល លោក អាប់ឌុលហាក់ សុំការបញ្ជាក់បន្ថែមទៅលើតួនាទីរបស់ប្រធាន ៨៧០ លោក ឆេនដល័រ បានឆ្លើយថាគាត់យល់ដឹងពីរឿងនេះកាន់តែច្បាស់ពីដីកាដំណោះស្រាយ ។ បន្ទាប់មក លោក ឆេនដល័រ បាននិយាយថា ៨៧០គឺជាលេខកូដឈ្មោះ ប៉ុល ពត ហើយមន្ទីរ៨៧០គឺធ្វើការគ្រប់គ្រងទៅលើឯកសារ និងលំហូរចេញចូលរបស់មជ្ឈិមបក្ស និយាយជារួមគឺ«ការងារបែបការិយាល័យ» ។ លោកបានធ្វើសេចក្តីសន្និដ្ឋានដោយធ្វើការបង្ហាញពីភាពច្របូកច្របល់ថាតើ ប្រធានមន្ទីរអាច

ជា ខៀវ សំផន ឬ ខៀវ ឬ ប៉ុល ពត ដោយរបៀបណា? ឬមន្ទីរនោះគ្រប់គ្រងជារួម ។ លោក បានធ្វើកំណត់សម្គាល់ថា «ចំណុចទាំងនេះមានលក្ខណៈជាន់គ្នា ដែលជាហេតុធ្វើឲ្យមានការលំបាកក្នុងការឲ្យនិយមន័យ» ។

## ការជំទាស់បន្តបន្ទាប់ទៅលើប្រភពនៃសក្ខីកម្មរបស់ ឆេនដល័រ

លោក ហ្សាស្តេ ប៉ៅ បានធ្វើការជំទាស់ទៅលើការពិភាក្សារបស់សាក្សីទាក់ទងនឹងដីកាដំណោះស្រាយ ។ បន្ទាប់ពីលោកបានលើកឡើងពីសេចក្តីសម្រេចពីមុនរបស់ចៅក្រម ខាត់រ៉ាយត៍ លោកបានសង្កត់ធ្ងន់ថា វាមានសារសំខាន់ដែលឲ្យសាក្សីបញ្ជាក់ម្តងទៀតពីឯកសារដែលមាននៅក្នុងដីកាដំណោះស្រាយ ឬបញ្ជាក់ថាសាក្សីពឹងផ្អែកទៅលើសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ។ លោក ប៉ៅ បានធ្វើកំណត់សម្គាល់ថាចំណុចនេះមានពាក់ព័ន្ធគ្នា ពីព្រោះមេធាវីការពារក្តីធ្វើការងារពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ។ នៅត្រង់ចំណុចនេះ លោក អាកទួរ វែកគែន ក៏បានយល់ស្របថា វាគឺជាចំណុចល្អប្រសិនបើសាក្សីអាចបញ្ជាក់ថា ខ្លួនសំដៅលើដីកាដំណោះស្រាយលើសំណុំរឿង០០១ ឬដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ។

លោក អាប់ឌុលហាក់ បានឆ្លើយតបថាអ្វីដែលតម្រូវឲ្យអ្នកជំនាញឆ្លើយតបគឺជា«ការងារដែលមិនអាចទៅរួច» ពីព្រោះដីកាដំណោះស្រាយមានលេខយោងរាប់ពាន់ ។ លោកបានអះអាងថា វាមិនសមហេតុសមផលដែលយើងសុំឲ្យសាក្សីរំឮកនូវអ្វីដែលសាក្សីបានអានពីព្រោះ ចៅក្រមបានជូនដំណឹងដល់អ្នកសាក្សីថាមិនចាំបាច់យកឯកសារអ្វីមកតាមខ្លួនទេ ។ លោកបានស្នើថាដំណោះស្រាយគឺយើងគួរតែសួរលោក ឆេនដល័រ អំពីប្រភពជាក់លាក់ដែលលោកបានផ្អែកទៅលើ និងការយល់ឃើញរបស់លោកមុនពេលមានដីកាដំណោះស្រាយ និងក្រោយពេលមានដីកាដំណោះស្រាយ ហើយថាតើការផ្លាស់ប្តូរនោះមានលក្ខណៈយ៉ាងដូចម្តេចដែរ?

លោក ខាណាវ៉ាស់ បានឆ្លើយតបដោយចោទជាសំណួរថាតើមេធាវីការពារក្តីត្រូវការពារក្តីដោយរបៀបណា ប្រសិនបើមេធាវីការពារក្តីមិនដឹងថា សាក្សីកំពុងតែសំដៅទៅលើចំណុចអ្វីនោះ ។ លោកបានឆ្លើយតបថា សំណើរបស់ចៅក្រម ខាត់រ៉ាយត៍ ដែលអនុញ្ញាតឲ្យសាក្សីត្រឹមតែនិយាយថា «ខ្ញុំបានអានវានៅក្នុងដីកាដំណោះស្រាយ» គឺជា«ការរកម្ជុលនៅក្នុងចំបើង» ។ លោកបានធ្វើសេចក្តីសន្និដ្ឋានថា «យើងមិនចង់បានចំបើងទេ យើងចង់បានម្ជុល» ។ លោក ប៉ៅ លើកឡើងថា លោក ខាណាវ៉ាស ត្រូវតែអាចបញ្ជាក់ពីប្រភពដែលលោក ឆេនដល័រ បានលើកឡើង ។ លោក ប៉ៅ

បាននិយាយថា ចំណុចចាប់ផ្ដើមគឺថាតើលោក ឆេនដល័រ បានផ្អែកលើប្រភពដីកាដំណោះស្រាយដែរឬទេ ។

បន្ទាប់ពីពិភាក្សាជាមួយចៅក្រមទាំងអស់ លោកប្រធាន និល ណុន បានជូនដំណឹងដល់ភាគីទាំងអស់ថា ៖

> ដើម្បីដំណើរការទៅមុខទៀត ខ្ញុំសូមសួរសាក្សីថាតើសាក្សីអាចបង្ហាញពីប្រភពឯកសារដែរឬទេ ប្រសិនបើមិនធ្វើដូច្នេះទេ មេធាវីការពារក្ដីនឹងលើកឡើងពីបញ្ហានេះនៅពេលក្រោយទៀតនៅពេលដែលខ្លួនមានឱកាសសួរសំណួរ ។ ប្រសិនបើយើងមានចម្ងល់ទៅលើសក្ដីកម្មរបស់សាក្សី ភាគីទាំងអស់មានឱកាសដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរនៅពេលក្រោយ ។ សុំបញ្ជាក់ថា វិសាលភាពនៃបញ្ហានេះមានលក្ខណៈទូលំទូលាយណាស់ ។ ដូចគ្នាដែរ ការងាររបស់លោក ឆេនដល័រ ក៏ទូលាយដែរ ដូច្នេះយើងត្រូវការពេលវេលាច្រើនដើម្បី ពិភាក្សាទៅលើកិច្ចការងាររបស់អ្នកជំនាញនេះ ។

នៅចំណុចនេះ លោក អាប់ឌុលហាក់ បានលើកឡើងពី«របៀបវារៈ»មួយដែលព្រះរាជអាជ្ញានឹងអនុវត្តនៅថ្ងៃនេះនិងថ្ងៃស្អែក ។ បន្ទាប់ពី«ស្វែងរកចំណុចសំខាន់សម្រាប់ការអភិវឌ្ឍបក្ស និងការវិវឌ្ឍបក្សមុនឆ្នាំ១៩៧៥» ព្រះរាជអាជ្ញានឹងពិភាក្សាអំពីស្ថាប័នរបស់របបកម្ពុជាប្រជាធិបតេយ្យ ការជម្លៀសដោយបង្ខំ គោលនយោបាយពីព្រោះវាមានជាប់ពាក់ព័ន្ធនឹងការបង្កើតសហករណ៍ និងការរស់នៅរួមគ្នា គោលនយោបាយទៅលើសត្រូវ និងទំនាក់ទំនងនៅក្នុងរបប ។

នៅចំណុចនេះលោក ឆេនដល័រ ចង់លើកពីយោបល់របស់ខ្លួនទៅលើការពិភាក្សាមុន ។ លោកបាននិយាយដោយមិនពេញចិត្តថា «ខ្ញុំមិនទាន់ឃើញសំណួរដែលខ្ញុំត្រូវឆ្លើយនៅថ្ងៃនេះទេ ហើយប្រសិនបើសំណួរទាំងនេះបានផ្ញើមកខ្ញុំ ខ្ញុំនឹងមកទីនេះក្នុងនាមជាសាក្សីមកទទួលការបណ្ដុះបណ្ដាល គឺមិនមែនសាក្សីជំនាញទេ» ។ វាមានភាពត្រឹមត្រូវដែលលោក ឆេនដល័រ បានកែប្រែគំនិតដើមដែលមាននៅក្នុងការស្រាវជ្រាវរបស់លោក ប៉ុន្តែវាមិនត្រឹមត្រូវដែលឲ្យលោកលើកឡើងពីលេខយោងឲ្យជាក់លាក់ថា «អូ! វានៅលេខយោង៨៩ ទំព័រ៣០៨» ។ លោកបានធ្វើសេចក្ដីសន្និដ្ឋានថា នេះគឺជាតម្រូវការដែលលោកមិនអាចធ្វើបាន ។

លោកប្រធាន និល ណុន បានធ្វើរំឭកដល់សាក្សីថាប្រសិនបើសាក្សីមិនអាចឆ្លើយបាន នោះសាក្សីត្រឹមតែឆ្លើយថាខ្លួនមិនអាចធ្វើបានហើយ ។

លោក ខាណាវ៉ាស បានធ្វើការជំទាស់ម្តងទៀតថា នៅថ្ងៃ១១ខែមិថុនាឆ្នាំ២០១២ មេធាវីការពារក្តីរបស់ អៀង សារី បានដាក់លិខិតទៅអង្គជំនុំជម្រះសាលាដំបូងដោយស្នើថាសាក្សីជំនាញគួរតែបង្ហាញពីប្រភពព័ត៌មានដែលខ្លួនបានពិនិត្យមើលដើម្បីជាការត្រៀមខ្លួនមកផ្តល់សក្ខីកម្ម ។ លោក ខាណាវ៉ាស បានលើកឡើងថា ព្រះរាជអាជ្ញាបានយល់ស្របនឹងចំណុចនេះ និងបន្ថែមទៀតថាសាក្សីមិន ចាំបាច់ពិនិត្យលើចំណុចផ្សេងទៀតទេ ។ លោកបានរំឭកថា នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១២ លោក ឆេនដល័រ បានទទួលលិខិតមួយស្នើឲ្យលោករៀបចំសង្ខេបឯកសារដាក់ក្នុងតារាងមុនពេលមកផ្តល់សក្ខីកម្ម ។ លោក ខាណាវ៉ាស បានអះអាងថាការធ្វើបែបនេះអាចធ្វើឲ្យសាក្សីអាចចង្អុលបង្ហាញពីកំណត់សម្គាល់ដែលសាក្សីបានធ្វើ ដើម្បីឲ្យមេធាវីការពារក្តីអាចពិនិត្យថាតើប្រភពនោះវាត្រូវនឹងអ្វីដែលសាក្សីបានលើកឡើងដែរឬទេ ។

បន្ទាប់ពីលោក អាប់ឌុលហាក់ បញ្ជាក់ថា ពិតជាមានសំណើឲ្យសាក្សីជំនាញរៀបចំតារាងនោះមែន លោក ឆេនដល័រ បាននិយាយថា លោកបានទទួលសំណើនោះ ប៉ុន្តែលោកមិនបានរៀបចំតារាងនោះទេ ។ លោកបានបញ្ជាក់ថា ពីរថ្ងៃមុនលោកបានអានដីកាដំណោះស្រាយលើសំណុំរឿង០០២ ។ លោកបាននិយាយថា លោកបានពិនិត្យមើលប្រភពដើមនៅពេលយប់មុនពេលនឹងលោកផ្តល់សក្ខីកម្ម ។ លោកមិនអាចបង្ហាញពីប្រភពចម្លើយរបស់លោកបានទេ ។ លោកអាចធ្វើដូច្នោះបានប្រសិនបើលោកអាចរៀបចំចម្លើយមុន ឬ“ប្រសិនបើលោកមកតុលាការបានរយៈពេលមួយខែ” ។

លោក អាប់ ឌុលហាក់ បានស្នើថាអង្គជំនុំជម្រះអាចបន្តទៅមុខបាន ពីព្រោះការត្រួតពិនិត្យភាគច្រើនរបស់ព្រះរាជអាជ្ញានឹងផ្អែកទៅលើឯកសារ ហើយនៅក្នុងករណីជាច្រើន ព្រះរាជអាជ្ញា នឹងសួរសាក្សី ឬសួរបន្ថែមទៅលើឯកសារ ដូច្នេះវាប្រហែលជាមិនបង្កើតជាបញ្ហាទេ ។

## ជម្លោះកើតឡើងនៅពេលដែលមានការចាំបាច់សុំឲ្យមានសវនាការនៅថ្ងៃសុក្រ

លោកប្រធាន និល ណុន បានប្រកាសថាដំណើរការនីតិវិធីនឹងបន្តនៅថ្ងៃស្អែក វេលាម៉ោង ៩ព្រឹក និងអញ្ជើញលោក ឆេនដល័រ ឲ្យមកបន្តផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះ ។ មុនពេលដែលលោកប្រធាន និល ណុន បិទដំណើរការនីតិវិធី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិនាំមុខ លោក ពេជអង្គ បានសួរថាតើនឹងមានសវនាការនៅថ្ងៃសុក្រ ដូចនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដែរឬទេ ។ លោកប្រធាន និល ណុន បានបង្ហាញថាលោកមិនបានទទួលសំណើនេះទេ ហើយលោកបានពន្យល់ថាជាទូទៅគឺមិនមានសវនាការនៅថ្ងៃសុក្រទេ ។ នឹងមានសវនាការនៅថ្ងៃសុក្រនៅក្នុងករណីដែលចាំបាច់

គឺនៅពេលដែលមានពេលវេលាដែលបានរៀបចំមិនដើរតាមពេលកំណត់ ។ លោកបានធ្វើកំណត់សម្គាល់ថាការធ្វើបែបនោះនឹងបណ្តាលឲ្យមានការផ្លាស់ប្តូរពេលវេលារបស់សាក្សីដែលនឹងមកផ្តល់សក្ខីកម្មដែរ ។

លោក ខាណាវ៉ាស់ បានលើកឡើងថា អ្នកទាំងអស់គ្នានឹងដើរតាមដំណើរការនីតិវិធីដដែល ពីព្រោះព្រះរាជអាជ្ញាមិនបានជូនដំណឹងដល់អង្គជំម្រះអំពីការពន្យារពេល ។ លោកបាននិយាយថា មន្ត្រីច្បាប់ជាន់ខ្ពស់មិនបានផ្តល់ការឆ្លើយតបរបស់ខ្លួនដល់អង្គជំនុំជម្រះ ដែល«ប្រហែលជាអាចបង្ហាញឲ្យឃើញពីភាពមិនស្របគ្នា» ។ លោកយល់ស្របថា បន្ទាប់ពីសវនាការនៅថ្ងៃនោះ អង្គជំនុំជម្រះបានពន្យារពេលសវនាពីរថ្ងៃដែលអាចបណ្តាលឲ្យមានសវនាការនៅថ្ងៃសុក្រ ប៉ុន្តែយើងបានទាក់ទងជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់អំពីបញ្ហាបើកសវនាការនៅថ្ងៃសុក្រ ។ លោក ខាណាវ៉ាស់ បានពន្យល់ថា លោកត្រូវទៅផ្តល់វគ្គបណ្តុះបណ្តាលស្តីពីស្ពានអន្តរជាតិនៃយុត្តិធម៌«International Bridges of Justice »នៅថ្ងៃសុក្រ ដូច្នេះលោកមិនអាចកែប្រែពេលវេលាមកចូលរួមសវនាការនៅថ្ងៃសុក្រទេ ។ ជាងនេះទៅទៀត លោកបានសង្កត់ធ្ងន់ថា «ប្រសិនបើអង្គជំនុំជម្រះយល់ស្របនឹងភាគីព្រះរាជអាជ្ញា ហើយបដិសេធនឹងភាគីមេធាវីការពារក្តីនោះវានឹងបង្ហាញឲ្យឃើញថាមានភាគីម្ខាងទទួលបានសិទ្ធិច្រើនជាងភាគីម្ខាងទៀត ។ នេះគឺជាស្ថានភាពដែលបង្កើតឡើងដោយព្រះរាជអាជ្ញាមិនមែនយើងទេ» ។ នៅទីបញ្ចប់ លោកបានបង្ហាញថាលោក ឆេនដល័រ ប្រហែលជាអាចចំណេញមួយថ្ងៃ ប៉ុន្តែនឹងទទួលការរិះគន់ដោយមេធាវីការពារក្តី ។ លោកបានធ្វើសេចក្តីសន្និដ្ឋានសំណើរបស់គាត់ថា មិនត្រូវមានសវនាការនៅថ្ងៃសុក្រទេ ។

លោក ប៉ាវ បានគាំទ្រនឹងសំណើរបស់លោក ខាណាវ៉ាស ហើយធ្វើសេចក្តីសន្និដ្ឋានថា លោកមេធាវីរបស់អៀង សារី មានសិទ្ធិតំណាងឲ្យកូនក្តីរបស់ខ្លួនក្នុងការជ្រើសរើស ។

បន្ទាប់ពីពិចារណាទៅលើបញ្ហានេះ លោកប្រធាន និល ណុន ទទួលស្គាល់អំពីបញ្ហានៃការពន្យារពេលសវនាការ ហើយបញ្ជាក់ថាអង្គជំនុំជម្រះនឹងសម្រេចទៅលើរឿងនេះ ហើយផ្តល់ដំណឹងដល់ភាគីនៅថ្ងៃស្អែក ។

លោកប្រធាន និល ណុន បានលើកឡើងពីចំណុចមួយទៀតថា អៀង សារី ត្រូវតែត្រឡប់មកបន្ទប់សវនាការវិញនៅថ្ងៃស្អែក ពីព្រោះរបាយការណ៍របស់វេជ្ជបណ្ឌិតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០១២ បានបញ្ជាក់ថាដោយសារតែជំងឺរបស់ អៀង សារី គាត់គួរតែទទួលការអនុញ្ញាតឲ្យសម្រាកនៅក្នុងបន្ទប់ឃុំឃាំង១០ថ្ងៃរហូតដល់ថ្ងៃទី២២ ខែកក្កដាឆ្នាំ ឆ្នាំ២០១២ ។

**-ចប់-**